កិំ សោ ភវមានោ សច្ចកោ ឯកន្តបុត្តោ យោ(๑) ភគវតោ ឯវំ អាវេវេស្សតិ អថខោ ភគវា សច្ចកស្ស ឯកន្តបុត្តស្ស ឯវំ អាវេវេស្សតីតិ ។ អថខោ សច្ចកោ ឯកន្តបុត្តោ បញ្ចមត្តេហិ លិច្ឆវិសតេហិ បរិវុតោ យេន មហាវនំ កូដាគារសាលា តេនុបសង្កមិ ។

(๓๕) តេន ខោ បន សមយេន សម្ពហុលា កិក្ខូ អព្ភោកាសេ ចង្កមន្តិ ។ អថខោ សច្ចកោ ឯកន្តបុត្តោ យេន តេ កិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ កិក្ខូ ឯតទវោច កហន្តេ ភោ ឯតរហិ សោ ភវំ គោតមោ វិហរតិ ឧស្សន្នោ ភាហំ មយំ តំ ភវន្តំ គោតមំ ។ ឯស អត្តិវេស្សន ភគវា មហាវនំ អជ្ឈោហរិត្វា អញ្ញតរស្មិំ រុក្ខមូលេ ឯកវិហារំ ឯសិន្នោតិ ។ អថខោ សច្ចកោ ឯកន្តបុត្តោ មហតិយា លិច្ឆវិបរិសាយ សទ្ធិំ មហាវនំ អជ្ឈោហរិត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា

---

๑ ម. យោតំ ន ទិស្សតិ ។

សច្ចកនិគន្ថបុត្រនោះ ទើសើកឡើងនូវពាក្យសំដី របស់ព្រះមានព្រះភាគជាម្ចាស់ ដូចម្តេចបាន មានតែព្រះមានព្រះភាគជាម្ចាស់ទេ ទើបលើកឡើងនូវពាក្យសំដី របស់សច្ចកនិគន្ថបុត្របាន ។ លំដាប់នោះ សច្ចកនិគន្ថបុត្រ មានព្រះបាទលិច្ឆវីចំនួនប្រាំរយអង្គចោមរោម ក៏ចូលសំដៅទៅត្រង់កូដាគារសាលា នាមហាវន ។

(៣៩) សម័យនោះឯង កិកុច្រើនរូបកំពុងចង្រ្កមនៅខ័ណ្ឌ ។ គ្រានោះ សច្ចកនិគន្ថបុត្រ ចូលទៅរកកិកុទាំងនោះ លុះចូលទៅដល់ហើយ ក៏ពោលពាក្យនេះនឹងកិកុទាំងនោះថា នែលោកទាំងឡាយដ៏ចំរើន ឥឡូវនេះ ព្រះគោតមដ៏ចំរើននោះ គង់នៅក្នុងទីណា យើងទាំងឡាយ ចង់ចូលទៅគាល់ព្រះគោតមដ៏ចំរើននោះ ។ កិកុទាំងនោះតបថា ម្នាលអគ្គិវេស្សនៈ ព្រះមានព្រះភាគជាម្ចាស់អង្គនុ៎ះ ទ្រង់យាងចូលទៅកាន់មហាវន គង់សម្រាកព្រះអង្គក្នុងវេលាថ្ងៃ ត្រាមមួយឈើមួយ ។ លំដាប់នោះសច្ចកនិគន្ថបុត្រ ក៏ចូលទៅកាន់មហាវន ជាមួយនឹងព្រះបាទលិច្ឆវីជាបរិស័ទច្រើនអង្គ ចូលទៅរកព្រះវិហារព្រះភាគ លុះចូលទៅដល់ហើយ

ភគវតា សទ្ធិំ សម្ពោធិំ សម្ពោធនិយំ កថំ សាក-
ណិយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ តេបិ
ខោ លិច្ឆវី អប្បេកច្ចេ ភគវន្តំ អភិវាទេត្វា ឯកមន្តំ
និសីទិំសុ ។ អប្បេកច្ចេ ភគវតា សទ្ធិំ សម្ពោធិំសុ
សម្ពោធនិយំ កថំ សាកណិយំ វីតិសារេត្វា ឯកមន្តំ
និសីទិំសុ ។ អប្បេកច្ចេ យេន ភគវា តេនញ្ជលិំ ប-
ណាមេត្វា ឯកមន្តំ និសីទិំសុ ។ អប្បេកច្ចេ ភគវតោ
សន្តិកេ នាមគោត្តំ សាវេត្វា ឯកមន្តំ និសីទិំសុ ។
អប្បេកច្ចេ តុណ្ហីភូតា ឯកមន្តំ និសីទិំសុ ។

(៣៦) ឯកមន្តំ និសិន្នោ ខោ សច្ចកោ និគណ្ឋបុត្តោ
ភគវន្តំ ឯតទវោច បុច្ឆេយ្យាហំ ភវន្តំ គោតមំ កញ្ចិទេវ
ទេសំ សចេ មេ ភវំ គោតមោ ឱកាសំ ករោតិ
បញ្ហស្ស វេយ្យាករណាយាតិ ។ បុច្ឆ អគ្គិវេស្សន
យទាកង្ខសីតិ ។ កថំ បន(๑) ភវំ គោតមោ សា-
វកេ វិនេតិ កថំការោ ច បន គោតោ គោតមស្ស
សាវកេសុ អនុសាសនិ ពាហុលា បវត្តតីតិ ។

---

๑ ម. ពហុវ ។

មហាយមកវគ្គ ចូឡសក្ខកសូត្រ ពាក្យប្រៀនប្រដៅដែលប្រព្រឹត្តទៅដោយច្រើន

ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ឯព្រះបាទលិច្ឆវីទាំងនោះ ពួកខ្លះ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ ពួកខ្លះ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏គង់ក្នុងទីដ៏សមគួរ ។ ពួកខ្លះ ក៏គង់ប្រណម្យអញ្ជលី ចំពោះព្រះមានព្រះភាគ ក្នុងទីដ៏សមគួរ ។ ពួកខ្លះ ក៏សំដែងនាមនឹងគោត្រ (របស់ខ្លួន) ឲ្យឮច្បាស់ក្នុងសំណាក់នៃព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ ពួកខ្លះ ក៏គង់នៅស្ងៀមក្នុងទីដ៏សមគួរ ។

(៣៦) សច្ចកនិគន្ថបុត្រ លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះនឹងព្រះមានព្រះភាគថា បើព្រះគោតមដ៏ចំរើន ធ្វើនូវឱកាសដើម្បីដោះស្រាយនូវបញ្ហារបស់ខ្ញុំបាន ខ្ញុំនឹងសួរនូវហេតុនីមួយ នឹងព្រះគោតមដ៏ចំរើន ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលវច្ឆគោត្រៈ បើអ្នកត្រូវការនឹងសួរ ចូរសួរមកចុះ ។ ព្រះគោតមដ៏ចំរើន តែងបុគ្គលពួកសាវ័កដូចម្តេចខ្លះ ពាក្យប្រៀនប្រដៅរបស់ព្រះគោតមដ៏ចំរើន តែងប្រព្រឹត្តទៅច្រើនក្នុងពួកសាវ័ក មានចំណែកដូចម្តេចខ្លះ ។ ម្នាល

ឯវំ ខោ អហំ អត្តវេរញ្ជេន សាវកេ វិនេមិ ឯវំភាគា ច
បន មេ សាវកេសុ អនុសាសនី ពហុលា ហវន្តិ រូបំ
តិក្ខវេ អនិច្ចំ វេទនា អនិច្ចា សញ្ញា អនិច្ចា
សង្ខារា អនិច្ចា វិញ្ញាណំ អនិច្ចំ រូបំ តិក្ខវេ អនត្តា
វេទនា អនត្តា សញ្ញា អនត្តា សង្ខារា អនត្តា
វិញ្ញាណំ អនត្តា សព្ពេ សង្ខារា អនត្តា សព្ពេ ធម្មា
អនត្តាតិ ឯវំ ខោ អហំ អត្តវេរញ្ជេន សាវកេ
វិនេមិ ឯវំភាគា ច បន មេ សាវកេសុ អនុសាសនី
ពហុលា ហវន្តីតិ ។ ឧបមា មំ កោ តោតម
បដិភាតីតិ ។ បដិភាតុ តំ អគ្គិវេស្សនាតិ តតោ
អវោច ។ សេយ្យថាបិ កោ តោតម យេ កេចិមេ
វិដភាមភូតគាមា(១) វុឌ្ឍិំ វិរូឡ្ហិំ វេបុល្លំ អាបជ្ជន្តិ
សព្ពេ តេ បឋវិំ និស្សាយ បឋវិយំ បតិដ្ឋាយ
ឯវមេវំ វិដភាមភូតគាមា វុឌ្ឍិំ វិរូឡ្ហិំ វេបុល្លំ
អាបជ្ជន្តិ សេយ្យថាបិ ភ បន កោ តោតម

---

១ ឧ. ម. ពីជគាមភូតគាមា ។

អគ្គិវេស្សនៈ តថាគតតែងទូន្មានពួកសាវ័កយ៉ាងនេះ ពាក្យប្រៀនប្រដៅរបស់តថាគត តែងប្រព្រឹត្តទៅច្រើនក្នុងពួកសាវ័ក មានចំណែកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង វេទនាមិនទៀង សញ្ញាមិនទៀង សង្ខារទាំងឡាយមិនទៀង វិញ្ញាណមិនទៀង ម្នាលភិក្ខុទាំងឡាយ រូបមិនមែនជាខ្លួន វេទនាមិនមែនជាខ្លួន សញ្ញាមិនមែនជាខ្លួន សង្ខារទាំងឡាយមិនមែនជាខ្លួន វិញ្ញាណមិនមែនជាខ្លួន សង្ខារទាំងពួងមិនមែនជាខ្លួន ធម៌ទាំងពួង ក៏មិនមែនជាខ្លួនដែរ ម្នាលអគ្គិវេស្សនៈ តថាគតតែងទូន្មានពួកសាវ័កយ៉ាងនេះឯង ពាក្យប្រៀនប្រដៅរបស់តថាគត តែងប្រព្រឹត្តទៅច្រើនក្នុងពួកសាវ័ក មានចំណែកយ៉ាងនេះ ។ បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គសូមសំដែងពាក្យឧបមាបន្តិច ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អើអគ្គិវេស្សនៈ អ្នកឯងចូរសំដែងពាក្យឧបមាទៅចុះ ។ បពិត្រព្រះគោតមដ៏ចំរើន ពីជគាមនឹងកូតគាមទាំងឡាយណានីមួយ ដល់នូវការចំរើន លូតលាស់ ធំទូលាយ ពីជគាមនឹងកូតគាមទាំងអស់នោះ អាស្រ័យនូវផែនដី តាំងនៅលើផែនដី ពីជគាមនឹងកូតគាមទាំងនុ៎ះ ក៏តែងតែដល់នូវការចំរើន លូតលាស់ ធំទូលាយយ៉ាងនេះ មានឧបមាដូចម្តេចមិញ បពិត្រព្រះគោតម ដ៏ចំរើន មួយទៀត

យេ កេចិ មេ ភាសេការណិយា កម្មន្តា កិរិយដ្ឋេ
សព្វេ តេ បហីនេ ឧស្សុក្កាយ បហីយំ បតិដ្ឋាយ ឯវមេវ
ភាសេការណិយា កម្មន្តា កិរិយដ្ឋេ ឯវមេវ ខោ កោ
កោតម រូបត្តាយំ បុរិសបុគ្គលោ រូបេ បតិដ្ឋាយ
បុញ្ញំ ឯ អបុញ្ញំ ឯ បសវតិ វេទនត្តាយំ បុរិសបុគ្គលោ
វេទនាយ បតិដ្ឋាយ បុញ្ញំ ឯ អបុញ្ញំ ឯ បសវតិ
សញ្ញត្តាយំ បុរិសបុគ្គលោ សញ្ញាយ បតិដ្ឋាយ
បុញ្ញំ ឯ អបុញ្ញំ ឯ បសវតិ សង្ខារត្តាយំ បុរិសបុគ្គ-
លោ សង្ខារេសុ បតិដ្ឋាយ បុញ្ញំ ឯ អបុញ្ញំ ឯ បសវតិ
វិញ្ញាណត្តាយំ បុរិសបុគ្គលោ វិញ្ញាណេ បតិដ្ឋាយ
បុញ្ញំ ឯ អបុញ្ញំ ឯ បសវតីតិ ។ ឥទ្ធំ តំ(១) អក្ខិវេសួន
ឯវំ វិទេសំ រូបំ មេ អត្តា វេទនា មេ អត្តា សញ្ញា
មេ អត្តា សង្ខារា មេ អត្តា វិញ្ញាណំ មេ អត្តាតិ ។
អបាំ ហិ កោ កោតម ឯវំ វិនាមិ រូបំ មេ អត្តា
វេទនា មេ អត្តា សញ្ញា មេ អត្តា សង្ខារា មេ អត្តា

---

๑ ម.ម. តុំ ។

យកមកនូវគ្គ ចូឡសច្ចកសូត្រ ពាក្យប្រៀនប្រដៅដែលប្រព្រឹត្តទៅដោយប្រុង

ការងារតាំងឡាយ ដែលគួរធ្វើដោយកំឡាំងណាមួយ គេតែងធ្វើការ

ងារទាំងអស់នោះ អាស្រ័យនូវផែនដី តាំងនៅលើផែនដី ការងារដែលគួរ

ធ្វើដោយកំឡាំងទាំងនុ៎ះ គេតែងធ្វើយ៉ាងនេះ មានឧបមាដូចម្តេចមិញ

បពិត្រព្រះគោតមដ៏ចំរើន បុរសបុគ្គលនេះ មានរូបជាខ្លួន តាំងនៅក្នុងរូប

ខ្លួនទូរបុណ្យឫបាប បុរសបុគ្គលនេះ មានវេទនាជាខ្លួន តាំងនៅក្នុង

វេទនា ខ្លួនទូរបុណ្យឫបាប បុរសបុគ្គលនេះ មានសញ្ញាជាខ្លួន តាំង

នៅក្នុងសញ្ញា ខ្លួនទូរបុណ្យឫបាប បុរសបុគ្គលនេះ មានសង្ខារជាខ្លួន

តាំងនៅក្នុងសង្ខារទាំងឡាយ ខ្លួនទូរបុណ្យឫបាប បុរសបុគ្គលនេះមាន

វិញ្ញាណជាខ្លួន តាំងនៅក្នុងវិញ្ញាណ ខ្លួនទូរបុណ្យឫបាប មានឧប-

មេយ្យដូចោះឯង ។ ម្នាលអគ្គិវេស្សនៈ អ្នកពោលពាក្យយ៉ាងនេះថា រូបជា

ខ្លួនរបស់អញ វេទនាជាខ្លួនរបស់អញ សញ្ញាជាខ្លួនរបស់អញ សង្ខារទាំង

ឡាយជាខ្លួនរបស់អញ វិញ្ញាណជាខ្លួនរបស់អញ ដូច្នេះឬ ។ បពិត្រព្រះ

គោតមដ៏ចំរើន ខ្ញុំឯងពោលយ៉ាងនេះថា រូបជាខ្លួនរបស់អញ វេទនាជា

ខ្លួនរបស់អញ សញ្ញាជាខ្លួនរបស់អញ សង្ខារទាំងឡាយជាខ្លួនរបស់អញ

វិញ្ញាណំ មេ អត្តាតិ អយញ្ច មហាតិ ជនតា តិដ្ឋតិ ។ តស្មាហំ តេ អក្ខិវេស្សន មហតិ ជនតា តិដ្ឋតិ វិជ្ជតិ ច អក្ខិវេស្សន សតិ យេវ ភវិ ន ព្ភវេតិ ។ អបិ ហិ តេ តោតម ឯវំ វិញ្ញាណំ មេ អត្តា វេទនា មេ អត្តា សញ្ញា មេ អត្តា សង្ខារា មេ អត្តា វិញ្ញាណំ មេ អត្តាតិ ។

(៣៧) តេនហិ អក្ខិវេស្សន តញ្ញេវេត្ថ(១) បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ(២) ព្យាករេយ្យាសិ តំ កិំ មញ្ញសិ អក្ខិវេស្សន រូបំ និច្ចំ វា អនិច្ចំ វា ទុក្ខំ វា សុខំ វា បរិណាមធម្មំ វា ឧបាទានក្ខន្ធំ វា ឧបាទានក្ខន្ធំ វា ឯតំ មម ឯសោ ហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ តោតម ។ វេទនា សញ្ញា សង្ខារា វិញ្ញាណំ និច្ចំ វា អនិច្ចំ វា ទុក្ខំ វា សុខំ វា បរិណាមធម្មំ វា ឧបាទានក្ខន្ធំ វា ឧបាទានក្ខន្ធំ វា ឯតំ មម ឯសោ ហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ តោតម ។ តស្មាតិហ អក្ខិវេស្សន យំ កិញ្ចិ រូបគតំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្ពំ រូបំ នេតំ មម នេសោ ហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្ពំ ។ យា កាចិ វេទនា អតីតានាគតបច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា សព្ពា វេទនា នេតំ មម នេសោ ហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្ពំ ។ យា កាចិ សញ្ញា អតីតានាគតបច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា សព្ពា សញ្ញា នេតំ មម នេសោ ហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្ពំ ។ យេ កេចិ សង្ខារា អតីតានាគតបច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា សព្ពេ សង្ខារា នេតំ មម នេសោ ហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្ពំ ។ យេ កេចិ វិញ្ញាណា អតីតានាគតបច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា សព្ពេ វិញ្ញាណា នេតំ មម នេសោ ហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្ពំ ។

---

๑ ម. តំយេវេត្ថ ។ ๒ ម. តំ ។

វិញ្ញាណជាខ្លួនរបស់អញ ពាំងប្រជុំជនជាច្រើននេះ គេក៏ថាដូច្នេះដែរ ។
នែអគ្គិវេស្សន: ឯប្រជុំជនជាច្រើនរបស់អ្នក នឹងធ្វើជាសំអាងម្តេចបាន
ម្នាលអគ្គិវេស្សន: អញ្ចើញ អ្នកដោះស្រាយតែពាក្យសំដីរបស់ខ្លួនចុះ ។
បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំនៅតែពោលយ៉ាងនេះថា រូបជាខ្លួនរបស់
អញ វេទនាជាខ្លួនរបស់អញ សញ្ញាជាខ្លួនរបស់អញ សង្ខារទាំងឡាយ
ជាខ្លួនរបស់អញ វិញ្ញាណជាខ្លួនរបស់អញ ។

(៣៧) ម្នាលអគ្គិវេស្សន: បើដូច្នោះ តថាគតនឹងត្រឡប់សួរទៅ
អ្នកក្នុងប្រស្នានេះវិញ ប្រស្នាគាប់ចិត្តអ្នកយ៉ាងណា អ្នកត្រូវដោះស្រាយ
នូវប្រស្នានោះ យ៉ាងនោះចុះ នែអគ្គិវេស្សន: អ្នកសំគាល់នូវហេតុនោះ
ដូចម្តេច ព្រះពជាជាខត្តិយ: ដែលបានមុទ្ធាភិសេកហើយ ដូចយ៉ាងព្រះ
ពជាបសេនទិកោសល តុំនោះសោត ដូចព្រះពជាអជាតសត្តុវេទេហិបុត្ត
ជាឥស្សរ: កន្ធដែនមគធ: មានអំណាចកន្ធដែនជារបស់ខ្លួន គប្បីប្រព្រឹត្ត
ដើម្បីសម្ងាប់នូវបុគ្គលដែលគួរសម្ងាប់ ដើម្បីរឹបជាន់នូវបុគ្គលដែលគួររឹប
ជាន់ ឬដើម្បីនិរទេសនូវបុគ្គលដែលគួរនិរទេស បានឬទេ ។ បពិត្រ
ព្រះគោតមដ៏ចំរើន ព្រះពជាជាខត្តិយ: ដែលបានមុទ្ធាភិសេកហើយ
ដូចយ៉ាងព្រះពជាបសេនទិកោសល តុំនោះសោត ដូចជាព្រះពជា
អជាតសត្តុវេទេហិបុត្ត ជាឥស្សរ: កន្ធដែនមគធ: មានអំណាចកន្ធ
ដែនជារបស់ខ្លួន គប្បីប្រព្រឹត្ត ដើម្បីសម្ងាប់នូវបុគ្គល ដែលគួរសម្ងាប់

ឧបោសថង្គានំ ច ឧបោសថង្គានញ្ច សង្ឃាដិយា ច សង្ឃាដិយញ្ច
សេយ្យថាបិ នាម រញ្ញោ បរិសេនទិស្ស តោសលិស្ស
សេយ្យថាបិ ច បន រញ្ញោ អាកិណ្ណស្ស វិវដ-
ស្សុស្ស វេទេហិបុត្តស្ស ឥមេសម្បិ(១) ហិ តោ
តោតម សង្ឃានំ គណានំ សេយ្យថីធំ វដ្ដិំ
បល្លង្កំ វត្តតិ សក្កស្មិំ វិជិតេ វសោ យាតេតាយំ ច
យាតេតុំ ជានេតាយំ ច ជានេតុំ បញ្ហាវេតាយំ ច
បញ្ហាវេតុំ តាទិ បន រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស
សេយ្យថាបិ រញ្ញោ បរិសេនទិស្ស តោសលិស្ស
សេយ្យថាបិ ច បន រញ្ញោ អាកិណ្ណស្ស អជាតសត្តុស្ស
វេទេហិបុត្តស្ស វត្តេយ្យ តោ តោតម វត្តុន្តុញ្ចមរហា-
តីតិ(២) ។ តំ តាទិ មញ្ញសិ អត្តវេសារជ្ជេ យំ ត្វំ ឋិំ
វេទេសិ ត្រូបំ មេ អត្តានំ វត្តតិ តេ តស្មិំ ត្រូបេ វសោ ឋិំ
មេ ត្រូបំ ហោតុ ឋិំ មេ ត្រូបំ មា អហោសីតិ ។ ឋិំ
ត្វេវ សត្ថុកោ ឯកន្តបុត្តោ តុណ្ហី អហោសិ ។ ទុតិ-
យម្បិ ខោ ភគវា សច្ចកិំ ឯកន្តបុត្តំ ឯតទវោច
តំ តាទិ មញ្ញសិ អត្តវេសារជ្ជេ យំ ត្វំ ឋិំ វេទេសិ

---

១ ម. ឥមេសំបិ ។ ២ ម. វត្តុំតុំ ច មរហតីតិ ។

ដើម្បីបំបាន់នូវបុគ្គលដែលគួរបំបាន់ ឬដើម្បីនិរាទេសនូវបុគ្គលដែលគួរនិរាទេសបាន បពិត្រព្រះគោតមដ៏ចំរើន ព្រោះថា សូម្បីក្សត្រិយ៍ទាំងអម្បាលនេះ ជាពួក ជាគណៈ ដូចពួកក្សត្រិយ៍ដែលនៅកងដែនវដ្ជី នឹងពួកក្សត្រិយ៍ដែលនៅកងដែនមល្ល: មានអំណាចកងដែនជារបស់ខ្លួនតែងប្រព្រឹត្តដើម្បីសម្ងាប់នូវបុគ្គលដែលគួរសម្ងាប់ ដើម្បីបំបាន់នូវបុគ្គលដែលគួរបំបាន់ ឬដើម្បីនិរាទេសនូវបុគ្គលដែលគួរនិរាទេសបាន នឹងបាច់ពោលថ្វីដល់ទៅអំណាចរបស់ព្រះពជាជាទត្តិយ: ដែលបានមុទ្ធាភិសេកហើយ ដូចយ៉ាងព្រះពជាបសេនទិកោសល ពុំនោះសោតដូចព្រះពជាអជាតសត្តុវេទេហិបុត្ត ជាឥស្សរៈកងដែនមគធ: បពិត្រព្រះគោតមដ៏ចំរើន អំណាចគប្បីប្រព្រឹត្តទៅ ទាំងគួរនឹងប្រព្រឹត្តទៅ ។ នែអគ្គិវេស្សន: អ្នកសំគាល់នូវហេតុនោះដូចម្តេច អ្នកពោលនូវរូបណាយ៉ាងនេះថា រូបជារបស់អញ អំណាចរបស់អ្នក ប្រព្រឹត្តទៅក្នុងរូបនោះថា រូបរបស់អញ ចូរយ៉ាងនេះទៅ រូបរបស់អញ ចូរកុំមានយ៉ាងនេះឡើយ បានឬទេ ។ កាលបើព្រះសាស្តា ទ្រង់ត្រាស់យ៉ាងនេះហើយ សច្ចកនិគន្ថបុត្រ ក៏នៅស្ងៀម ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះនឹងសច្ចកនិគន្ថបុត្រ ជាគំរប់ពីរដងថា នែអគ្គិវេស្សន: អ្នកសំគាល់នូវហេតុនោះ ថាដូចម្តេច អ្នកពោល នូវរូបណា យ៉ាងនេះថា

រូបំ មេ អត្តាតិ វត្តតិ តេ តស្មិំ រូបេ វសោ ឃវំ មេ រូបំ ហោតុ ឃវំ មេ រូបំ មា អហោសីតិ ។ ឃវំ វុត្តេ ឧត្តរិយម្បិ ខោ សច្ចកោ និគណ្ឋបុត្តោ តុណ្ហី អហោសិ ។ អថខោ ភគវា សច្ចកំ និគណ្ឋបុត្តំ ឯតទវោច ព្យាករោហិទានិ អគ្គិវេស្សន ទានិ តេ តុណ្ហីភូតា. វេស្ស កាលោ យោ ខោ(๑) អគ្គិវេស្សន តថាគតេន យាវតតិយំ សហធម្មិកំ បញ្ហំ បុដ្ឋោ ន ព្យាករេតិ ឯត្ថវេស្ស សត្តធា មុទ្ធា ផលិស្សតីតិ(๒) ។ តេន ខោ បន សមយេន វជិរបាណី យក្ខោ អយសំ វជិរំ អាទាយ អាទិត្តំ សម្បជ្ជលិតំ សំជោតិភូតំ សច្ចកស្ស និគណ្ឋបុត្តស្ស ឧបរិវេហាយ សណ្ឋិតោ(๓) ហោតិ សចាយំ សច្ចកោ និគណ្ឋបុត្តោ ភគវតា យាវតតិយំ សហធម្មិកំ បញ្ហំ បុដ្ឋោ ន ព្យាករេតិ(๔) ឯត្ថវេស្ស សត្តធា មុទ្ធិ ផាលេស្សាមីតិ ។ តំ ខោ បន វជិរបាណិំ យក្ខំ ភគវា ចេវ បស្សតិ សច្ចកោ ច និគណ្ឋបុត្តោ ។ អថខោ សច្ចកោ និគណ្ឋបុត្តោ ភីតោ សំវិគ្គោ

---

๑ ឧ. ម យោ កោចិ ។ ๒ ឧ. ម. ផលតីតិ ។ ๓ ឧ. ម. ឧបរិវេហាសំ បិតា ។ ๔ ឧ. ម. ន ព្យាករិស្សតិ ។

រូបជាខ្លួនរបស់អញ អំណាចរបស់អ្នក ប្រព្រឹត្តទៅក្នុងរូបនោះថា រូប
របស់អញចូរយ៉ាងនេះទៅ រូបរបស់អញកុំយ៉ាងនេះឡើយ ចានប្តូរ ។
កាលព្រះសាស្តាទ្រង់ត្រាស់យ៉ាងនេះហើយ សច្ចកនិគន្ថបុត្រក៏នៅស្ងៀម
ជាគំរប់ពីរដង ។ លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះ នឹង
សច្ចកនិគន្ថបុត្រថា នែអគ្គិវេស្សន: អ្នកចូរដោះស្រាយនូវបញ្ហាក្នុងកាល
ឥឡូវនេះទៅ កាលឥឡូវនេះមិនមែនជាកាលអ្នកស្ងៀមទេ នែអគ្គិវេស្សន:
អ្នកណាមួយ ដែលតថាគតសួរនូវបញ្ហាប្រកបដោយធម៌ ជាគំរប់ ៣ ដង
ហើយ នៅតែមិនដោះស្រាយ ក្បាលរបស់អ្នកនោះ នឹងបែកជា ៧
ភាគ ក្នុងទីនុ៎ះពុំខាន ។ សម័យនោះឯង មានយក្សម្នាក់ឈ្មោះវជិរ-
បាណី(•) កាន់ដែកដូចជាកែវជិរ ដែលឆេះព្រាលន្ទាលភ្លឺសន្ធោសន្ធៅ
មកសណ្ឋិតនៅឰដ៏អាកាស ជាខាងលើនៃសច្ចកនិគន្ថបុត្រ ពោលពាក្យ
ដូច្នេះថា បើសច្ចកនិគន្ថបុត្រនេះ ដែលព្រះមានព្រះភាគទ្រង់សួរបញ្ហា
ប្រកបដោយធម៌ ជាគំរប់ ៣ ដងហើយ នៅតែមិនដោះស្រាយ អញ
នឹងបំបែកក្បាលរបស់សច្ចកនិគន្ថបុត្រនោះ ជា ៧ ភាគ ក្នុងទីនេះឯង ។
ព្រះមានព្រះភាគនឹងសច្ចកនិគន្ថបុត្រ ក៏បានឃើញយក្សឈ្មោះវជិរបាណី
នោះប្រាកដ ។ គ្រានោះឯង សច្ចកនិគន្ថបុត្រ ភ័យ តក់ស្លុត រន្ធត់

• ព្រះពន្ធ ។

เลาหมหาปฐวีเตา กตวาฬิยา ตาฬานิ กเรยฺย กตวาฬิ-
ยา เลฬานิ กเรยฺย กตวาฬิยา สรานิ กเรยฺย กตวาฬิ
ฬนฺตเรจ ปุจฺฉตุ มํ กรํ โกตมโก ฌาปกวิสฺสชฺชนตฺถ ฯ

(๓๘) ตตฺร กถญฺหิ นาม อายสฺมา นนฺทเสน ยนฺนูน
ฬรูปเทสนาย รูปเมว อตฺตโต วทฺเทยฺย เตน หิ รูเปน
วาเทน ฬรูปเมว เหตุ ฬรูปเมว ปจฺจโย ฬรูปเมว
อเหตุ ฬรูปเมว อปฺปจฺจโย ฯ เตน หิ ตุมฺเห โภนฺโต
มนสิกโรถ อตฺตวิสฺสชฺชนา มนสิกรณา ขเณ
อตฺตวิสฺสชฺชนา ฌาปกโรถ ฯ ขเณ เต สญฺญิตฺถ
ปุริเมน ปจฺฉิมสฺส ปจฺฉิเมน ปุริมสฺส ตตฺร กถญฺหิ
นาม อายสฺมา นนฺทเสน ยนฺนูน ฬรูปเทสนาย เวทนา
เมว อตฺตโต วทฺเทยฺย เตน หิ เวทนาย วาเทน ฬรู
เมว เวทนา เหตุ ฬรู เมว เวทนา มา อเหตุ-
สฺมินฺติ ฯ เตน หิ ตุมฺเห โภนฺโต มนสิกโร-
โถ อตฺตวิสฺสชฺชนา มนสิกรณา ขเณ อตฺตวิสฺสชฺชนา

ก็ในพระนคร ๆ ก็อาฬวกยักษ์ ได้ยินว่า เป็นผู้มีปัญญามาก อาฬวกยักษ์ ได้ยินว่า เป็นผู้ฉลาด อาฬวกยักษ์ ได้ยินว่า เป็นผู้มีความเห็นแจ้งว่าไม่มีความกลัว ครั้นได้ทราบข่าวว่า ได้ยินว่า พระสมณโคดมเสด็จมาถึงพระนครอาฬวี ก็ได้เกิดกิตติศัพท์ดีงามขึ้นอย่างนี้ว่า พระผู้มีพระภาคเจ้านั้น ทรงเป็นพระอรหันต์ ตรัสรู้ชอบเองโดยชอบ ถึงพร้อมด้วยวิชชาและจรณะ เสด็จไปดี ทรงรู้แจ้งโลก ทรงเป็นสารถีฝึกบุรุษที่ควรฝึกได้ดังนี้ ฯ ครั้งนั้น อาฬวกยักษ์ ได้เข้าไปเฝ้าพระผู้มีพระภาคเจ้าถึงที่ประทับ ครั้นแล้วได้กราบทูลพระผู้มีพระภาคเจ้าดังนี้ว่า ข้าแต่พระสมณโคดม ขอพระสมณโคดมจงเสด็จออกไปจากที่นี้ ข้าพระองค์ไม่ปรารถนาจะให้พระสมณโคดมเสด็จเข้ามาในที่นี้ ฯ แม้ครั้งที่ ๒ ... แม้ครั้งที่ ๓ ... ก็ได้กราบทูลพระผู้มีพระภาคเจ้าดังนี้ว่า ข้าแต่พระสมณโคดม ขอพระสมณโคดมจงเสด็จออกไปจากที่นี้ ข้าพระองค์ไม่ปรารถนาจะให้พระสมณโคดมเสด็จเข้ามาในที่นี้ ฯ แม้ครั้งที่ ๓ พระผู้มีพระภาคเจ้าก็ได้ตรัสกับอาฬวกยักษ์ดังนี้ว่า ดูกรอาฬวกะ เราจักเข้าไปก็ตาม จักไม่เข้าไปก็ตาม ท่านจงถามปัญหาในสำนักของเราเถิด ฯ

[๓๘] ม. ดูกรอัคคิเวสสนะ ท่านสำคัญข้อนั้นว่าอย่างไร ท่านกล่าวสอนสาวกทั้งหลายอย่างนี้ว่า รูปของเรา ฉันใด รูปในอดีตก็ฉันนั้น รูปในอนาคตก็จักเป็นฉันนั้น รูปในปัจจุบันก็เป็นฉันนั้น ดังนี้ หรือ ฯ อ. ข้าแต่พระสมณโคดม ข้าพเจ้าไม่กล่าวสอนสาวกทั้งหลายอย่างนี้ว่า รูปของเรา ฉันใด รูปในอดีตก็ฉันนั้น รูปในอนาคตก็จักเป็นฉันนั้น รูปในปัจจุบันก็เป็นฉันนั้น ดังนี้ ฯ ม. ดูกรอัคคิเวสสนะ ท่านสำคัญข้อนั้นว่าอย่างไร ท่านกล่าวสอนสาวกทั้งหลายอย่างนี้ว่า เวทนาของเรา ฉันใด เวทนาในอดีตก็ฉันนั้น เวทนาในอนาคตก็จักเป็นฉันนั้น เวทนาในปัจจุบันก็เป็นฉันนั้น ดังนี้ หรือ ฯ อ. ข้าแต่พระสมณโคดม ข้าพเจ้าไม่กล่าวสอนสาวกทั้งหลายอย่างนี้ว่า เวทนาของเรา ฉันใด เวทนาในอดีตก็ฉันนั้น เวทนาในอนาคตก็จักเป็นฉันนั้น เวทนาในปัจจุบันก็เป็นฉันนั้น ดังนี้ ฯ ม. ดูกรอัคคิเวสสนะ ท่านสำคัญข้อนั้นว่าอย่างไร ท่านกล่าวสอนสาวกทั้งหลายอย่างนี้ว่า สัญญาของเรา ฉันใด สัญญาในอดีตก็ฉันนั้น สัญญาในอนาคตก็จักเป็นฉันนั้น สัญญาในปัจจุบันก็เป็นฉันนั้น ดังนี้ หรือ ฯ อ. ข้าแต่พระสมณโคดม ข้าพเจ้าไม่กล่าวสอนสาวกทั้งหลายอย่างนี้ว่า สัญญาของเรา ฉันใด สัญญาในอดีตก็ฉันนั้น สัญญาในอนาคตก็จักเป็นฉันนั้น สัญญาในปัจจุบันก็เป็นฉันนั้น ดังนี้ ฯ ม. ดูกรอัคคิเวสสนะ ท่านสำคัญข้อนั้นว่าอย่างไร ท่านกล่าวสอนสาวกทั้งหลายอย่างนี้ว่า สังขารของเรา ฉันใด สังขารในอดีตก็ฉันนั้น สังขารในอนาคตก็จักเป็นฉันนั้น สังขารในปัจจุบันก็เป็นฉันนั้น ดังนี้ หรือ ฯ อ. ข้าแต่พระสมณโคดม ข้าพเจ้าไม่กล่าวสอนสาวกทั้งหลายอย่างนี้ว่า สังขารของเรา ฉันใด สังขารในอดีตก็ฉันนั้น สังขารในอนาคตก็จักเป็นฉันนั้น สังขารในปัจจุบันก็เป็นฉันนั้น ดังนี้ ฯ ม. ดูกรอัคคิเวสสนะ ท่านสำคัญข้อนั้นว่าอย่างไร ท่านกล่าวสอนสาวกทั้งหลายอย่างนี้ว่า วิญญาณของเรา ฉันใด วิญญาณในอดีตก็ฉันนั้น วิญญาณในอนาคตก็จักเป็นฉันนั้น วิญญาณในปัจจุบันก็เป็นฉันนั้น ดังนี้ หรือ ฯ อ. ข้าแต่พระสมณโคดม ข้าพเจ้าไม่กล่าวสอนสาวกทั้งหลายอย่างนี้ว่า วิญญาณของเรา ฉันใด วิญญาณในอดีตก็ฉันนั้น วิญญาณในอนาคตก็จักเป็นฉันนั้น วิญญาณในปัจจุบันก็เป็นฉันนั้น ดังนี้ ฯ ม. ดูกรอัคคิเวสสนะ ท่านสำคัญข้อนั้นว่าอย่างไร รูปเที่ยงหรือไม่เที่ยง ฯ อ. ข้าแต่พระสมณโคดม ไม่เที่ยง ฯ ม. ดูกรอัคคิเวสสนะ ก็สิ่งใดไม่เที่ยง สิ่งนั้นเป็นทุกข์หรือเป็นสุข ฯ อ. ข้าแต่พระสมณโคดม เป็นทุกข์ ฯ ม. ดูกรอัคคิเวสสนะ ก็สิ่งใดไม่เที่ยง เป็นทุกข์ มีความแปรปรวนเป็นธรรมดา สิ่งนั้นควรตามเห็นว่า นั่นของเรา นั่นเราเป็น นั่นอัตตาของเรา ดังนี้ หรือ ฯ อ. ข้าแต่พระสมณโคดม ไม่ควร ฯ ม. ดูกรอัคคิเวสสนะ ท่านสำคัญข้อนั้นว่าอย่างไร เวทนาเที่ยงหรือไม่เที่ยง ฯ อ. ข้าแต่พระสมณโคดม ไม่เที่ยง ฯ ม. ดูกรอัคคิเวสสนะ ก็สิ่งใดไม่เที่ยง สิ่งนั้นเป็นทุกข์หรือเป็นสุข ฯ อ. ข้าแต่พระสมณโคดม เป็นทุกข์ ฯ ม. ดูกรอัคคิเวสสนะ ก็สิ่งใดไม่เที่ยง เป็นทุกข์ มีความแปรปรวนเป็นธรรมดา สิ่งนั้นควรตามเห็นว่า นั่นของเรา นั่นเราเป็น นั่นอัตตาของเรา ดังนี้ หรือ ฯ อ. ข้าแต่พระสมณโคดม ไม่ควร ฯ ม. ดูกรอัคคิเวสสนะ ท่านสำคัญข้อนั้นว่าอย่างไร สัญญาเที่ยงหรือไม่เที่ยง ฯ อ. ข้าแต่พระสมณโคดม ไม่เที่ยง ฯ ม. ดูกรอัคคิเวสสนะ ก็สิ่งใดไม่เที่ยง สิ่งนั้นเป็นทุกข์หรือเป็นสุข ฯ อ. ข้าแต่พระสมณโคดม เป็นทุกข์ ฯ ม. ดูกรอัคคิเวสสนะ ก็สิ่งใดไม่เที่ยง เป็นทุกข์ มีความแปรปรวนเป็นธรรมดา สิ่งนั้นควรตามเห็นว่า นั่นของเรา นั่นเราเป็น นั่นอัตตาของเรา ดังนี้ หรือ ฯ อ. ข้าแต่พระสมณโคดม ไม่ควร ฯ ม. ดูกรอัคคิเวสสนะ ท่านสำคัญข้อนั้นว่าอย่างไร สังขารเที่ยงหรือไม่เที่ยง ฯ อ. ข้าแต่พระสมณโคดม ไม่เที่ยง ฯ ม. ดูกรอัคคิเวสสนะ ก็สิ่งใดไม่เที่ยง สิ่งนั้นเป็นทุกข์หรือเป็นสุข ฯ อ. ข้าแต่พระสมณโคดม เป็นทุกข์ ฯ ม. ดูกรอัคคิเวสสนะ ก็สิ่งใดไม่เที่ยง เป็นทุกข์ มีความแปรปรวนเป็นธรรมดา สิ่งนั้นควรตามเห็นว่า นั่นของเรา นั่นเราเป็น นั่นอัตตาของเรา ดังนี้ หรือ ฯ อ. ข้าแต่พระสมณโคดม ไม่ควร ฯ ม. ดูกรอัคคิเวสสนะ ท่านสำคัญข้อนั้นว่าอย่างไร วิญญาณเที่ยงหรือไม่เที่ยง ฯ อ. ข้าแต่พระสมณโคดม ไม่เที่ยง ฯ ม. ดูกรอัคคิเวสสนะ ก็สิ่งใดไม่เที่ยง สิ่งนั้นเป็นทุกข์หรือเป็นสุข ฯ อ. ข้าแต่พระสมณโคดม เป็นทุกข์ ฯ ม. ดูกรอัคคิเวสสนะ ก็สิ่งใดไม่เที่ยง เป็นทุกข์ มีความแปรปรวนเป็นธรรมดา สิ่งนั้นควรตามเห็นว่า นั่นของเรา นั่นเราเป็น นั่นอัตตาของเรา ดังนี้ หรือ ฯ อ. ข้าแต่พระสมณโคดม ไม่ควร ฯ ม. ดูกรอัคคิเวสสนะ ท่านสำคัญข้อนั้นว่าอย่างไร

ព្រាកភេហិ ន ខោ តេ សន្ធ័យតិ បុរិមេន ភ បច្ឆិមំ
បច្ឆិមេន ភ បុរិមំ តំ កី មញ្ញសិ អក្តិវេស្សន
យំ ត្វំ ឃំ វេទសិ សញ្ញា មេ អត្តាតិ វត្តតិ តេ
តាយ សញ្ញាយ វេសេ ឃំ មេ សញ្ញា ហោតុ
ឃំ មេ សញ្ញា មា អហោសីតិ ។ ឥោ ហិនំ
កោ កោតម ។ មនសិកភេហិ អក្តិវេស្សន
មនសិកវិត្វា ខោ អក្តិវេស្សន ព្រាកភេហិ ន
ខោ តេ សន្ធ័យតិ បុរិមេន ភ បច្ឆិមំ បច្ឆិមេន ភ
បុរិមំ តំ កី មញ្ញសិ អក្តិវេស្សន យំ ត្វំ ឃំ
វេទសិ សង្ខារ មេ អត្តាតិ វត្តតិ តេ តេសុ
សង្ខារេសុ សេ ឃំ មេ សង្ខារ ហោន្តុ ឃំ មេ
សង្ខារ មា អហោសុន្តិ ។ ឥោ ហិនំ កោ កោតម ។
មសិកភេហិ អក្តិវេស្សន មនសិកវិត្វា ខោ

រួចហើយ ចូរដោះស្រាយចុះ ព្រោះពាក្យខាងចុងរបស់អ្នកមិនជាប់គ្នានឹងពាក្យខាងដើមទេ ឬពាក្យខាងដើមរបស់អ្នក ក៏មិនជាប់គ្នានឹងពាក្យខាងចុងដែរ នែអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះថាដូចម្តេច អ្នកពោលនូវសញ្ញាណា យ៉ាងនេះថា សញ្ញាជារបស់អញ អំណាចរបស់អ្នកប្រព្រឹត្តទៅកាន់សញ្ញានោះថា សញ្ញារបស់អញ ចូរយ៉ាងនេះ សញ្ញារបស់អញចូរកុំយ៉ាងនេះឡើយ ឬទេ ។ បពិត្រព្រះគោតមដ៏ចំរើន ហេតុនេះមិនមានទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកចូរធ្វើទុកក្នុងចិត្តចុះ នែអគ្គិវេស្សនៈ លុះអ្នកធ្វើទុកក្នុងចិត្តរួចហើយ ចូរដោះស្រាយចុះ ព្រោះពាក្យខាងចុងរបស់អ្នក មិនជាប់គ្នានឹងពាក្យខាងដើមទេ ឬពាក្យខាងដើមរបស់អ្នក ក៏មិនជាប់គ្នានឹងពាក្យខាងចុងដែរ នែអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះ ថាដូចម្តេច អ្នកពោលនូវសង្ខារណាយ៉ាងនេះថា សង្ខារទាំងឡាយជារបស់អញ អំណាចរបស់អ្នក ប្រព្រឹត្តទៅកាន់សង្ខារទាំងនោះថា សង្ខារទាំងឡាយរបស់អញ ចូរយ៉ាងនេះទៅ សង្ខារទាំងឡាយរបស់អញ ចូរកុំយ៉ាងនេះឡើយ ឬទេ ។ បពិត្រព្រះគោតមដ៏ចំរើន ហេតុនេះមិនមានទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកចូរធ្វើទុកក្នុងចិត្តចុះ នែអគ្គិវេស្សនៈ លុះអ្នកធ្វើទុកក្នុងចិត្តរួចហើយ ចូរដោះស្រាយចុះ

អត្តវេសច្ឆេ ព្យាករោហំ ន ខោ តេ សន្ធិយតិ បុរិមេន វ បច្ឆិមំ បច្ឆិមេន វ បុរិមំ តំ កិំ មញ្ញសិ អត្តវេសច្ឆេ យំ នុ ឥទំ វិញ្ញាណំ មេ អត្តាតិ វត្តតិ តេ តស្មឹ វិញ្ញាណេ វិសេ ឥទំ មេ វិញ្ញាណំ ហោតុ មេ វិញ្ញាណំ មា អហោសីតិ ។ ខោ ហំ ឥ ភោ គោតម ។ មនសិករោហំ អត្តវេសច្ឆេ មនសិករិត្វា ខោ អត្តវេសច្ឆេ ព្យាករោហំ ន ខោ តេ សន្ធិយតិ បុរិមេន វ បច្ឆិមំ បច្ឆិមេន វ បុរិមំ តំ កិំ មញ្ញសិ អត្តវេសច្ឆេ រូបំ និច្ចំ វាតិ ។ អនិច្ចំ វាតិ ។ អនិច្ចំ ភោ គោតម ។ យំ បនានិច្ចំ ទុក្ខំ វ តំ សុខំ វាតិ ។ ទុក្ខំ ភោ គោតម ។ យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ ខោ ហោតំ ភោ គោតម ។ តំ កិំ មញ្ញសិ អត្តវេសច្ឆេ វេទនា... សញ្ញា...

ព្រោះពាក្យខាងចុងរបស់អ្នក មិនជាប់តគ្នានឹងពាក្យខាងដើមទេ ឬពាក្យខាងដើមរបស់អ្នក ក៏មិនជាប់តគ្នានឹងពាក្យខាងចុងដែរ នែអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះ ថាដូចម្តេច អ្នកពោលនូវវិញ្ញាណណាយ៉ាងនេះថា វិញ្ញាណជាខ្លួនរបស់អញ អំណាចរបស់អ្នក ប្រព្រឹត្តទៅក្នុងវិញ្ញាណនោះថា វិញ្ញាណរបស់អញ ចូរយ៉ាងនេះទៅ វិញ្ញាណរបស់អញ ចូរកុំយ៉ាងនេះឡើយ ឬ ? បពិត្រព្រះគោតមដ៏ចំរើន ហេតុនេះមិនបានទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកចូរធ្វើទុកក្នុងចិត្តចុះ នែអគ្គិវេស្សនៈ លុះអ្នកធ្វើទុកក្នុងចិត្តរួចហើយ ចូរដោះស្រាយចុះ ព្រោះពាក្យខាងចុងរបស់អ្នក មិនជាប់តគ្នានឹងពាក្យខាងដើមទេ ឬពាក្យខាងដើមរបស់អ្នក ក៏មិនជាប់តគ្នានឹងពាក្យខាងចុងដែរ នែអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះ ថាដូចម្តេច រូបទៀងឬមិនទៀង ។ បពិត្រព្រះគោតមដ៏ចំរើន រូបមិនទៀងទេ ។ របស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះគោតមដ៏ចំរើន របស់នោះជាទុក្ខ ។ ចុះរបស់ណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ឬទេ ។ បពិត្រព្រះគោតមដ៏ចំរើន មិនគួរឃើញយ៉ាងនុ៎ះទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះថាដូចម្តេច វេទនា ... សញ្ញា ...

សង្ខារ... វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។
អនិច្ចំ ភោ គោតម ។ យំ បនានិច្ចំ ទុក្ខំ វា
តំ សុខំ វាតិ ។ ទុក្ខំ ភោ គោតម ។ យំ
បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្ល នុ តំ សមនុ-
បស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ
អត្តាតិ ។ នោ ហេតំ ភោ គោតម ។ តំ កិំ
មញ្ញសិ អក្ខវេស្សន យោ នុ ខោ ទុក្ខំ អល្លីនោ
ទុក្ខំ ឧបគតោ ទុក្ខំ អជ្ឈោសិតោ ទុក្ខំ ឯតំ
មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ
អបិ នុ ខោ សោ សាមំ វា ទុក្ខំ បរិជានេយ្យ
ទុក្ខំ វា បរិក្ខេបេត្វា វិហរេយ្យាតិ ។ កិញ្ចិ សិយា
ភោ គោតម នោ ហិទំ ភោ គោតមាតិ ។ តំ
កិំ មញ្ញសិ អក្ខវេស្សន នុ ត្វំ ឯវំ សន្តេ ទុក្ខំ
អល្លីនោ ទុក្ខំ ឧបគតោ ទុក្ខំ អជ្ឈោសិតោ ទុក្ខំ
ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ
សមនុបស្សសីតិ ។ កិញ្ចិ .នោ សិយា ភោ គោតម
ឯវមេតំ ភោ គោតមាតិ ។

សង្ខារទាំងឡាយ... វិញ្ញាណទៀង ឬមិនទៀង ។ បពិត្រព្រះគោតមដ៏ចំរើន វិញ្ញាណមិនទៀងទេ ។ ចុះរបស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះគោតមដ៏ចំរើន របស់នោះជាទុក្ខ ។ ចុះរបស់ណាដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ឬទេ ។ បពិត្រព្រះគោតមដ៏ចំរើន មិនគួរឃើញយ៉ាងនុ៎ះទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះថាដូចម្តេច បុគ្គលណាស្ថិតជាបន្ទាប់សេចក្តីទុក្ខ ប្រកបនឹងសេចក្តីទុក្ខ លិចចុះទៅកាន់សេចក្តីទុក្ខ ឃើញនូវសេចក្តីទុក្ខថា នុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះ ហើយ បុគ្គលនោះគប្បីកំណត់ដឹងនូវសេចក្តីទុក្ខដោយខ្លួនឯងបាន ឬថាគប្បីធ្វើសេចក្តីទុក្ខឲ្យអស់ទៅបាន តើមានឬទេ ។ បពិត្រព្រះគោតមដ៏ចំរើន នឹងមានដូចម្តេចបាន បពិត្រព្រះគោតមដ៏ចំរើន ហេតុនេះមិនមានទេ ។ ម្នាលអគ្គិវេស្សនៈ អ្នកសំគាល់នូវហេតុនោះថា ដូចម្តេច កាលបើមានហេតុយ៉ាងនេះ ក្រែងអ្នកជាបុគ្គលជាប់ស្អិតនឹងសេចក្តីទុក្ខ ប្រកបនឹងសេចក្តីទុក្ខ លិចចុះទៅកាន់សេចក្តីទុក្ខហើយ ឃើញសេចក្តីទុក្ខថា នុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះមែនឬ ។ បពិត្រព្រះគោតមដ៏ចំរើន ថ្វីក៏មិនមានដូច្នោះ បពិត្រព្រះគោតមដ៏ចំរើន ហេតុនុ៎ះយ៉ាងនេះឯង ។

[๓๙] เอวเมฺม สุตฺตเมกสฺมึ สมเย ภควา สาวตฺถิยํ วิหรติ เชตวเน อนาถปิณฺฑิกสฺส อาราเม[๑] อถ โข อายสฺมา ปุณฺโณ เยน ภควา เตนุปสงฺกมิ อุปสงฺกมิตฺวา ภควนฺตเมตทโวจ สาธุ เม ภนฺเต ภควา สงฺขิตฺเตน ธมฺมํ เทเสตุ ยมหเมตฺถ ภควโต ธมฺมเทสนาย สุตฺวา ปจฺเจกา วิหเรยฺยนฺติ ตตฺร โข ภควา อายสฺมนฺตเมว ปุณฺณมุขฺขึ อามนฺเตสิ ตสฺมาติห ปุณฺณ ยเทว ตุมฺหากเมว ปฏิภาเนยฺย ตถา ตฺวเมว ปุณฺณ ปฏิภาเนยฺยาสิ มา ตฺวเมว ปุณฺณ ปฏิภาเนยฺยาสิ มา ตุมฺหากเมว ปฏิภาเนยฺยาสิ มา ตุมฺหากเมว ปฏิภาเนยฺยาสิ ยเทว ตุมฺหากเมว ปฏิภาเนยฺยาสิ ตถา ตฺวเมว ปุณฺณ ปฏิภาเนยฺยาสิ มา ตฺวเมว ปุณฺณ ปฏิภาเนยฺยาสิ มา ตุมฺหากเมว ปฏิภาเนยฺยาสิ มา ตุมฺหากเมว ปฏิภาเนยฺยาสิ ยเทว ตุมฺหากเมว ปฏิภาเนยฺยาสิ ตตฺร โข อายสฺมา ปุณฺโณ ภควโต ภาสิตมภินนฺทิตฺวา ปฏิกฺโกสิตฺวา อุฏฺฐายาสน

៧៩ ម្នាលអគ្គិវេស្សន: ដូចដូច្នោះដែរ បុរសអ្នកត្រូវការដោយខ្ញុំមេឈើ ស្វែងរកខ្ញុំមេឈើ ដើរទៅស្វែងរកខ្ញុំមេឈើ ក៏កាន់យកនូវដង្ហើមដ៏មុតច្បាស់ ទៅកាន់ព្រៃ បុរសនោះឃើញដើមចេកធំ ក្នុងព្រៃនោះ មានដើមត្រង់ សាច់ខ្ចី មិនទាន់កើតមានសួលសួង ហើយកាត់នូវដើមចេកនោះត្រង់គល់ លុះកាត់គល់រួចហើយ ក៏កាត់ចុង លុះកាត់ចុងរួចហើយ បកស្រទបចេញ កាលដែលបុរសនោះបកស្រទបចេញ ក៏មិនគប្បីបាន សូម្បីនូវស្រាយ ក្នុងដើមចេកនោះឡើយ ទំាងបានខ្ចឹមមកពីណា សេចក្តីនេះមានឧបមា យ៉ាងណាមិញ នែអគ្គិវេស្សន: អ្នកដែលតថាគតជជីកសួរដេញដោល ក៏ទៅជាមនុស្សសោះសូន្យទទេឥតខ្ចឹមសារ ចាលចាញ់ក្នុងវាទៈរបស់ខ្លួន មានឧបមេយ្យដូចដើមចេកដូច្នោះឯង នែអគ្គិវេស្សន: មួយទៀត វាចានេះ អ្នកបានពោលហើយ នាកណ្ណាលបរិស័ទ ក្រុងវេសាលីថា បុគ្គលណាដែលអាត្មាលើកឡើងនូវទោស ដោយពាក្យសំដីហើយ មិនកក្រើក មិនរំភើប មិនញាប់ញ័រ ទាំងញើសក៏មិនហូរចេញអំពីភ្លៅ របស់បុគ្គលណា អាត្មាមិនបានឃើញនូវបុគ្គលនោះ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ដែលមានពួកមានគណៈ ជាអាចារ្យនៃគណៈ ប្រកបាន ប្តេជ្ញាខ្លួនថាជាអរហន្តសម្មាសម្ពុទ្ធទេ ឯអាត្មា បើគប្បីលើកឡើងនូវទោស ដោយពាក្យសំដីចំពោះទៅលើបង្គោល ដែលជារបស់គ្មានចេតនាសោះ

សាធំ មយា កតេន កុសលេន សមារទ្ធា សង្ឃមេវយ្យ
សមេវ្យកមេវ្យយ្យ សមេវ្យវេនេយ្យ កោ បន កតោ
អនុសេវ្យកេវ្យសេវ្យតំ តុយ្ហំ ខោ បន អត្តវេសេវ្យន
អមេវ្យកេវ្យានំ សេនាសនានំ នលាជមុត្តានំ (๑)
ឧត្តរសន្តំ វនេវ្យនេវ្យា ភូមិយំ បតិដ្ឋានំ មយ្ហំ ខោ
បន អត្តវេសេវ្យន នត្ថិ ឯតរហិ កាយស្មឹ សេនោតិ ។
ឥតិ កតកា តស្មឹ បវិសតិ សុវណ្ណវណ្ណំ កាយំ
ទិវេ ។ ឯវំ វុត្តេ សច្ចកោ និគណ្ឋបុត្តោ តុណ្ហីភូតោ
មង្កុភូតោ បត្តក្ខន្ធោ អធោមុខោ បជ្ឈាយន្តោ អប្បដិ.
ភាណោ និសីទិ ។

(๒๑) អថខោ ភគវា សច្ចកំ និគណ្ឋបុត្តំ តុណ្ហីភូតំ
មង្កុភូតំ បត្តក្ខន្ធំ អធោមុខំ បជ្ឈាយន្តំ អប្បដិភាណំ វិទិត្វា ភគវន្តំ ឯតទវោច

๑ ម. ន. នលាជា មុត្តានំ ។

បង្គាលនោះ លុះអាត្មាលើកឡើងនូវទោស ដោយពាក្យសំដីហើយ
កំគប្បីកក្រើក រំភើប ញាប់ញ័រមិនខាន និយាយទៅចូដល់មនុស្សជាតផង្គា ម្នាលអគ្គិវេស្សនៈ ចំណែកអ្នកមានដំណាក់ញើសខ្លះ ហូរចេញអំពីថ្ងាសទំលុះសំពត់បង់ក ហើយធ្លាក់ទៅដក់លើផែនដីហើយ នែអគ្គិវេស្សនៈ ឯតថាគត ឥឡូវនេះ ឥតមានញើសក្នុងកាយទេ ។ ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគទ្រង់បើក នូវព្រះកាយ(១) ដែលមានសម្បុរដូចជាពណ៌នៃមាស ក្នុងបរិស័ទនោះ ។ កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សច្ចកនិគន្ថបុត្ត ក៏អង្គុយស្ងៀម អៀនអន់ ជាក់កសំយុង មុខចុះក្រោម ជ្រប់ស្រងូត មិនភ្ញៀវភ្លា ។

(៤០) គ្រានោះឯង លិច្ឆវិបុត្រឈ្មោះទុម្មុខៈ ដ៏ឆ្លាស់ថា សច្ចកនិគន្ថបុត្ត ស្ងៀម អៀនអន់ ជាក់កសំយុង មុខចុះក្រោម ជ្រប់ស្រងូត មិនភ្ញៀវភ្លា ហើយក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះ

---

១ ព្រះអង្គបើកកាយនោះ មិនមែនបើកកាយទាំងអស់ទេ ព្រោះទំនៀមព្រះពុទ្ធត្រាប់ព្រះអង្គ តែងពាក់ក្តុំបំទស់រឹះហើយសំដែងធម៌ក្នុងប្រជុំបរិស៎ទ្យ ។ ក្នុងកាលនោះព្រះមានព្រះភាគទ្រង់ចាប់យកចីវរ ទ្រង់បំពង់ព្រះឃ្លាងខាងមុខទំលាក់ចុះ ប្រមាណប៉ុន ៤ ឆ្នាប់ ។

ฉฬงฺคา ปิ กตกา ปฏิกาตพฺพา ฯ ปฏิกาตุ ปิ ปุคฺคลา
กตกา อกตกา ฯ เสยฺยถาปิ กตฺถ ปพฺพชิตสฺส ปิ
ฉินฺนหตฺถสฺส ปิ อาทิมฺหิ เจว มชฺเฌ จ ปริยนฺเต จ ฉินฺนตฺตา
อกตโก กตฺถ สพฺพโส กุมารกา ปิ กุมาริกา
ปิ ตตฺถ ตาทิส ปิ ฉินฺนหตฺถ ปิ ฉินฺนปาท ยาน สา
เจติกฺขณี เตนุปสงฺกมิตพฺพา อุปสงฺกมิตฺวา ตสฺ เจติกฺข-
ณิ ทิสฺวาเยว ตสฺ ตสฺ กิจฺจสฺส อุฏฺฐาตพฺพ อุฏฺฐหิตฺวา ฉเฬ
ปติฏฺฐาเปตพฺพ ยญฺจสฺ ตตฺถ กิจฺจ ตสฺ ตสฺ กิจฺจสฺส อตฺถ
อภิฉินฺทิตพฺพ ตตฺเรว เต กุมารกา ปิ กุมาริกา ปิ
กฏฺฐ ปิ กมฺม ปิ สญฺเจตฺวา ปิ สมฺปฺเจตฺวา ปิ สมฺป-
ลิกปฺเจตฺวา ปิ ฆาตพฺพ เยว กตฺถ กิจฺจสฺส สพฺพหิ
อาเปตพฺพ สญฺเจตฺตพฺพ สมฺปฺเจตพฺพ สมฺปลิกปฺเจตพฺพ อ-
กปฺเป ตสฺ เจติกฺขณี ปุน ทิสฺวาปิ ปุเรปิ ปจฺฉาปิ
ฆาตเมว เจติ กตฺถ ยาน สตฺถกสฺส ปิตฺตปุตฺตสฺส วิสฺส-
กายิตาน วิเสวิตาน วิปฺปฏิสาร กาน ปิ กาน ปิ ตาน
กตฺวาปิ สญฺเจตฺตาน สมฺปฺเจตาน สมฺปลิกปฺเจตาน อกปฺเป
จตาน กตฺถ สตฺถกา ปิตฺตปุตฺตา ปุน กตฺวาปิ

มานព្រះភាគ ខ្ញុំព្រះអង្គសូមសំដែងពាក្យឧបមាបន្តិច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលទុម្មុខៈ ចូរអ្នកសំដែងពាក្យឧបមានោះទៅមើល ។ បពិត្រព្រះអង្គដ៏ចំរើន ដូចជាស្រះបោក្ខរណីនៅជិតស្រុកឬនិគម មានក្តាមនៅក្នុងស្រះបោក្ខរណីនោះ បពិត្រព្រះអង្គដ៏ចំរើន លំដាប់នោះ ក្មេងប្រុសឬក្មេងស្រីតាំងឡាយជាច្រើន ចេញអំពីស្រុកឬនិគមនោះ ចូលទៅកាន់ស្រះបោក្ខរណី លុះចូលទៅដល់ហើយ ក៏ចុះទៅកាន់ស្រះបោក្ខរណីនោះ ហើយចាប់ក្តាមនោះស្រង់អំពីទឹក មកដាក់នៅលើគោក បពិត្រព្រះអង្គដ៏ចំរើន ក្តាមនោះហាចេញនូវដង្កៀបណា ។ ក្មេងប្រុសឬក្មេងស្រីតាំងនោះ ក៏កាច់បំបាក់បំបែកនូវដង្កៀបនោះ ។ ដោយកំណាត់ឈើក្តី ដោយអំបែងក្តី បពិត្រព្រះអង្គដ៏ចំរើន កាលបើយ៉ាងនេះហើយ ក្តាមនោះដែលមានដង្កៀបតាំងអស់ គេកាច់បំបាក់បំបែកអស់ហើយ មិនគួរដើម្បីនឹងចុះទៅកាន់ស្រះបោក្ខរណីនោះទៀតឡើយដូចកាលមុនទេ មានឧបមាដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចំរើន សេចក្តីចំរើនឬសេចក្តីវិនាស ពុតត្បុតតែជាសេចក្តីនឹងសេចក្តីញាប់ញ័រតែក្នុងវិជ្ជាណាមួយ របស់សច្ចកនិគន្ថបុត្រ ក៏សេចក្តីចំរើនឬសេចក្តីវិនាសដើមនោះ ព្រះមានព្រះភាគទ្រង់កាច់បំបាក់បំបែកហើយ បពិត្រព្រះអង្គដ៏ចំរើន កាលឥឡូវនេះ សច្ចកនិគន្ថបុត្រមិនគួរនឹងមានសេចក្តីប្រាថ្នាថា នឹងលើកឡើងនូវវាទៈ ចូលទៅរកព្រះមានព្រះភាគទៀតទេ

อุปสงฺกมิตุํ ยนฺติ ภควนฺตมฺปายาตา ฯ ฯปฯ วุตฺเต สตฺถาปิ ตุณฺหีภาเวน อธิวาเสสิ. อถ โข เต ปริพฺพาชกา ตุณฺหีภูตมฺปิ สตฺถารํ อาคเมหิ ภนฺเต ภควา อาคเมหิ ภนฺเต สุคโต อาคเมหิ ภนฺเต สุคโต กาลมญฺญสิ ภนฺเต ภควาติ อุฏฺฐายาสนา ปกฺกมึสุ.(๑) อถ โข ภควา ตสฺสา รตฺติยา อจฺจเยน ปุพฺพณฺหสมยนฺติ นิวาเสตฺวา ปตฺตจีวรมาทาย สาวตฺถิยา ปิณฺฑาย ปาวิสิ. ตตฺร สุทนฺตา ปริพฺพาชกา ภควนฺตมฺปายาตา ฯ ฯปฯ วุตฺเต สตฺถาปิ ตุณฺหีภาเวน อธิวาเสสิ. อถ โข เต ปริพฺพาชกา ตุณฺหีภูตมฺปิ สตฺถารํ อาคเมหิ ภนฺเต ภควา อาคเมหิ ภนฺเต สุคโต อาคเมหิ ภนฺเต สุคโต กาลมญฺญสิ ภนฺเต ภควาติ อุฏฺฐายาสนา ปกฺกมึสุ.(๑) ๘ มยญฺจ ตาว สนฺติ มนฺตเม ๘ มยญฺจ โภนฺตา โภตเมน สนฺติ มนฺตเม ตสฺสาปิ โภ โภตม อมฺหากญฺจ อาจริยสฺส ปุพฺพสมณา. ปฺราหฺมณานญฺจ ภควาวิลาปิ วิลปิตเมว มญฺเญ ฯ

(๒๑) ตตฺราวาตา ๘ ตุ ขฺวา โภ โภ. มสฺส สาวโก สาสนกโร โหติ ติฏฺฐติ. กโร ตณฺหาวิตกฺกโญ วิตกฺกวิจารา วาจาสงฺขารา เวทนาสญฺญาสงฺขารา อปราปฺปจฺจยา สตฺต สาสเน วิหารตีติ ฯ ๘ อตฺถิเวสฺสน มม สาวโก ยมิ ตณฺหา รูปี อตีตา. ตาคตปฺปจฺจุปฺปนฺเน อชฺฌตฺตญฺจ ๘ ตหิทฺธา ๘ ทุกฺขาตกา ๘ สุขุมี ๘ หีนา ๘ ปณีตา ๘ ยา ทูเร สนฺติเก ๘ สพฺพา รูปี เนตา มม เนโสหมสฺมิ ๘ เมโส อตฺตาติ วิเมตา ยถาภูตา สมฺมปฺปญฺญาย

---

๑ ฉ. ม. ปุเรเวสิ ตุณฺหีภาตา ๘ ทิสฺสติ ฯ

មានទុបមេយ្យដូច្នោះឯង ។ កាលបើខ្ញុំមានវិចិច្ឆវិបុត្ត និយាយយ៉ាងនេះ
ហើយ សច្ចកនិគន្ថបុត្រក៏ពោលពាក្យនេះទៅនឹងខ្ញុំមានលិច្ឆវិបុត្តថា នែ
ខ្ញុំមាន: អ្នកចូរឈប់សិន នែខ្ញុំមាន: អ្នកចូរឈប់សិន នែខ្ញុំមាន: អ្នកជា
បុគ្គលមានមាត់រឹង យើងមិនមែនប្រឹក្សា ជាមួយនឹងអ្នកទេ ក្នុងទីនេះ
យើងនឹងប្រឹក្សាជាមួយព្រះគោតមដ៏ចំរើនថា បពិត្រព្រះគោតមដ៏ចំរើន
វាចានេះ ជាវាចារបស់យើងភាំងឮ្លាយផង របស់សមណព្រាហ្មណ៍ដ៏
ច្រើនដទៃផង ចូរស្ងៀមទុកចុះ ការបញ្ចេញនូវវាចានេះ ក៏ហាក់ដូចជា
គ្រាន់តែនិយាយទៅទេ ។

(៤១) សច្ចកនិគន្ថបុត្រ ក្រាបបង្គំទូលសួរថា សាវ័កបស់ព្រះ
គោតមដ៏ចំរើន ជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ប្រព្រឹត្តតាមដំបូន្មាន
ប្រព្រឹត្តកន្លងនូវសេចក្តីសង្ស័យហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ហើយ
ដល់នូវសេចក្តីក្លៀវក្លា មិនដឿអ្នកដទៃ ក្នុងសាសនានៃព្រះសាស្តា ដោយ
ហេតុមានប៉ុន្មានយ៉ាង ។ ម្នាលអគ្គិវេស្សន: រូបណាមួយ ជាអតីត
អនាគត ទំាងបច្ចុប្បន្ន ជារូបខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រោតក្តី ល្អិត
ក្តី ថោកទាបក្តី ខ្ពស់ក្តី មួយទៀត រូបណានៅក្នុងទីឆ្ងាយក្តី ក្នុងទីជិត
ក្តី រូបទាំងអស់នោះ ជានឈ្មោះថារូប សាវ័កបស់តថាគតក្នុងសាសនា

ปสฺสถ ฯ ยา กาจิ เวทนา ฯ เป ฯ ยา กาจิ สญฺญา... เย เกจิ สงฺขารา... ยงฺกิญฺจิ วิญฺญาณํ อตีตานาคตปจฺจุปฺปนฺนํ อชฺฌตฺตํ วา พหิทฺธา วา โอฬาริกํ วา สุขุมํ วา หีนํ วา ปณีตํ วา ยงฺ ทูเร สนฺติเก วา สพฺพํ วิญฺญาณํ เนตํ มม เนโสหมสฺมิ น เมโสตฺถ อตฺตาติ เอวเมตํ ยถาภูตํ สมฺมปฺปญฺญาย ปสฺสถ ฯ เอตฺตาวตา โข อกฺกิเลสฺสน มม สาวโกติ สาสนกาโร เหาติ ขุทฺทกปฏิกาโรติ ตีณฺณาวิจิกิจฺโฉ วิคตกถงฺกถีติปิ เวสารชฺชปฺปตฺโต อปรปฺปจฺจโย สตฺถุ สาสเน วิหารตีติ ฯ

នេះ តែងឃើញនូវរូបនុ៎ះតាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ វេទនាណានីមួយ ។ បេ ។ សញ្ញាណានីមួយ... សង្ខារទាំងឡាយណានីមួយ... វិញ្ញាណណានីមួយ ជាអតីត អនាគត នឹងបច្ចុប្បន្ន ជាវិញ្ញាណ ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី មួយទៀត វិញ្ញាណណា ដែលមាននៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី វិញ្ញាណទាំងអស់នោះ ឋានឈ្មោះថាវិញ្ញាណ សាវ័កបស់តថាគតតែងឃើញនូវវិញ្ញាណនុ៎ះ តាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ នែអគ្គិវេស្សនៈ សាវ័កបស់តថាគត ជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ប្រព្រឹត្តតាមដំបូន្មាន ប្រព្រឹត្តកន្លងសេចក្តីសង្ស័យហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ហើយ ដល់នូវសេចក្តីក្លៀវក្លា មិនជឿបុគ្គលដទៃក្នុងសាសនានៃព្រះសាស្តា ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។

(៤២) កតិស្សាវតា បន ភោ គោតម កត្ថុ អវមាំ
ឃោតំ ខីណាសវេ វុសិតវា កតករណីយេ ឱហិត-
ភារេ អនុប្បត្តសទត្ថោ បរិក្ខីណភវសញ្ញោជនោ សម្ម-
ទញ្ញាវិមុត្តោតិ ។ ៥ អត្ថិស្សេវ កត្ថុ យំ តំញ្ញូ រូបំ
អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិ-
កំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិ-
កេ វា សព្ពំ រូបំ នេតំ មម នេសោហមស្មិ ន មេសា
អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អនុ-
បាទាវិមុត្តោ ហោតិ ។ យា តាចំ វេទនា... យា តាចំ
សញ្ញា... យេ តេចំ សង្ខារា... យំ តំញ្ញូ វិញ្ញាណំ
អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា
ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ

(๔๒) សច្ចកនិគន្ថបុត្តក្រាបទូលសួរថា បពិត្រព្រះគោតមដ៏ចំរើន កិរិយាដែលឈ្មោះថាអរហន្តខីណាស្រព មានព្រហ្មចារ្យនៅរួចហើយ មានសោឡសកិច្ចធ្វើរួចហើយ មានគ្រឿងធ្ងន់ដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានសំយោជន: ក្នុងភពអស់ហើយ មានចិត្តរួចស្រឡះហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ ដោយហេតុមានប្រមាណប៉ុន្មាន ។ ម្នាលអគ្គិវេស្សន: រូបណានីមួយ ជាអតីត អនាគត នឹងបច្ចុប្បន្ន ជារូបខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកថាបក្តី ខ្ពស់ក្តី មួយទៀត រូបណាមាននៅកងទីឆ្ងាយក្តី កងទីជិតក្តី រូបទាំងអស់នោះ ឋានឈ្មោះថារូប តថាគតសាសនានេះ មានចិត្តផុតស្រឡះហើយ ដោយមិនមានសេចក្តីប្រកាន់មាំ ព្រោះឃើញនូវរូបនុ៎ះតាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ វេទនាណានីមួយ... សញ្ញាណានីមួយ... សង្ខារទាំងឡាយណានីមួយ.. វិញ្ញាណណានីមួយ ជាអតីត អនាគត នឹងបច្ចុប្បន្ន ជាវិញ្ញាណខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកថាបក្តី ខ្ពស់ក្តី មួយទៀត វិញ្ញាណណា

ทุวเร สนฺติเก ฯ สพฺเพ ปิญฺจกามคุณิเก ธเม มม ธเมฺมหิ สทฺธึ ธมฺมิ ฯ มเมสา อตฺตาติ ฯ ปวาเทติ ยถาภูตสมฺมปฺปญฺญาย ทิสฺวา อนุปาทาวิมุตฺโต โหติ ฯ ปฏิฺญาตา โข อกิตฺติเสฏฺฐิน ภิกฺขู อรหนฺโต โหนฺติ ขีณาสวาติ ฯ ปุถุชฺชนภาวกตกรณียา ฉินฺนภวสโยชนาติ อนุปฺปตฺตสทฺธตฺตา ปหีนกิเลสาสฺเวน สมฺมทญฺญาวิมุตฺตา(๑) ฯ ฉฬภิ ิญฺญาวิมุตฺตา(๒) โข อกิตฺติเสฏฺฐิน ภิกฺขู ตีหาทุตฺตริเยหิ(๓) สมนฺนาคตา โหนฺติ ทสฺสนาทุตฺตริเยน ปฏิปทาทุตฺตริเยน วิมุตฺตาทุตฺตริเยน ฯ ฉฬภิ ิญฺญาวิมุตฺตจิตฺตา อกิตฺติเสฏฺฐิน ภิกฺขู ตถาคตสฺเสว สกฺกาเรติ ครุกาเรติ มาเนติ ปูเชติ

---

๑ ฉ. ม. วิมุตฺตาติ ฯ ๒ ฉ. ม. วิมุตฺตจิตฺตา ฯ ๓ ฉ. ม. ตีหิ อาทุตฺตริเยหิ ฯ

មហាយមកវគ្គ ភូឡសច្ចកសុត្រ ការពិចារណាសង្ខារថាមិនមែនខ្លួន

មានន័យកន្លងទៅឆ្ងាយក្តី កន្លងទៅជិតក្តី វិញ្ញាណទាំងអស់នោះ ឯងឈ្មោះថាវិញ្ញាណ កិកុមានចិត្តផុតស្រឡះហើយ ដោយមិនមានសេចក្តីប្រកាន់មាំ ព្រោះឃើញនូវវិញ្ញាណនុ៎ះ តាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ ម្នាលអគ្គិវេស្សន: កិកុដែលឈ្មោះថាអរហន្តខីណាស្រព មានព្រហ្មចារ្យនៅរួចហើយ មានសោឡសកិច្ចធ្វើរួចហើយ មានគ្រឿងទម្ងន់ដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានសំយោជន:កន្លងកពអស់ហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។ ម្នាលអគ្គិវេស្សន: លុះកិកុនោះ មានចិត្តផុតស្រឡះយ៉ាងនេះហើយ តែងប្រកបដោយអនុត្តរិយ: ទាំង ៣ គឺ ទស្សនានុត្តរិយ:១(១) បដិបទានុត្តរិយ:១(២) វិមុត្តានុត្តរិយ:១(៣) ។ ម្នាលអគ្គិវេស្សន: កិកុមានចិត្តផុតស្រឡះយ៉ាងនេះហើយ តែងធ្វើសក្ការ: គោរព កប់អាន បូជានូវតថាគតដោយគតិតថា

---

១ បានដល់បញ្ញាជាលោកិយ:ទើងលោកុត្តរ: ។ ២ បានដល់បដិបទាជាលោកិយ:ទើងលោកុត្តរ: ។ ៣ បានដល់វិមុត្តិជាលោកុត្តរ: ។ ម្យ៉ាងទៀត បើសង្គ្រោះយកលោកុត្តរសុទ្ធតែ ទស្សនានុត្តរិយ: បានដល់អរហត្តមគ្គ សម្មាទិដ្ឋិ ។ បដិបទានុត្តរិយ: បានដល់អង្គមគ្គដ៏សេស មានសម្មាសង្កប្បៈជាដើម ។ វិមុត្តានុត្តរិយ: បានដល់មគ្គ ផល វិមុត្តិ ។ អ្នកប្រាជ្ញគប្បីដឹងថា ការឃើញផ្លូវព្រះនិព្វានរបស់ព្រះខីណាស្រព ហៅថា ទស្សនានុត្តរិយ: ។ អង្គមគ្គទាំង៨ ហៅថា បដិបទានុត្តរិយ: ។ មគ្គ ផល ហៅថា វិមុត្តានុត្តរិយ: ។ អដ្ឋកថា ។

តុណ្ហោ សោ ភគវា តោដាយ ឆម្ពំ នេសេតិ អន្តោ សោ ភគវា ឧមដាយ ឆម្ពំ នេសេតិ សន្តោ សោ ភគវា ឧមដាយ ឆម្ពំ នេសេតិ តំណ្ហោ សោ ភគវា តរណាយ ឆម្ពំ នេសេតិ បរិដ្ឌាតោ សោ ភគវា បរិញ្ញាយ ឆម្ពំ នេសេតីតិ ។

(៤៣) យំ ភុត្តេ សម្ពុតោ ឯតទដ្ឋបុត្តោ ភគវន្តំ ឯតទវោច មយមេវ តោ តោតម ឥមំ មយំ បតិញ្ញាយេ មយំ ភវន្តំ តោតមំ ភាទេន ភាទំ អាសាទេតព្ពំ អមញ្ញិម្ហ សាយោ ហិ តោ តោតម ហត្ថី បតិដ្ឋំ អាសជ្ជ បុរិសស្ស សោត្ថិភាវេ ន ត្វេវ ភវន្តំ តោតមំ អាសជ្ជ សាយោ បុរិសស្ស សោត្ថិភាវេ សាយោ ហិ តោ តោតម បជ្ជលិតំ(១) អគ្គិក្ខន្ធំ អាសជ្ជ បុរិសស្ស សោត្ថិភាវេ

---

១ ម. ជលន្តំ ។

ព្រះមានព្រះភាគអង្គនោះ ទ្រង់ត្រាស់ដឹងនូវសច្ចធម៌ទាំង ៤ ហើយ ទ្រង់សំដែងធម៌ ដើម្បីញុំាងពួកជនដទៃឲ្យត្រាស់ដឹងផង ព្រះមានព្រះភាគអង្គនោះ ព្រះអង្គទូន្មាននូវតន្ត្រៃយហើយ ទ្រង់សំដែងធម៌ ដើម្បីញុំាងសត្វឲ្យទូន្មាននូវតន្ត្រៃយ ព្រះមានព្រះភាគអង្គនោះ ព្រះអង្គបានរម្ងាប់បង់នូវកិលេសហើយ ទ្រង់សំដែងធម៌ ដើម្បីញុំាងសត្វឲ្យរម្ងាប់បង់នូវកិលេស ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្លង (នូវអន្ទង់ទាំង ៤) ហើយ ទ្រង់សំដែងធម៌ ដើម្បីញុំាងសត្វឲ្យឆ្លងនូវអន្ទង់ទាំង ៤ ព្រះមានព្រះភាគអង្គនោះ ព្រះអង្គរំលត់នូវកិលេសហើយ ទ្រង់សំដែងធម៌ ដើម្បីញុំាងសត្វឲ្យរំលត់កិលេស ។

(៤៣) កាលដែលព្រះមានព្រះភាគ ទ្រង់សំដែងយ៉ាងនេះហើយ សច្ចកនិគន្ថបុត្រ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គជាអ្នកតំាតស់បង់នូវគុណ ខ្ញុំព្រះអង្គជាអ្នកឃ្លើសឃ្លង់ដោយវាចា ព្រោះហេតុថាខ្ញុំព្រះអង្គបានសំគាល់នូវព្រះគោតមដ៏ចំរើន ថាជាបុគ្គលគួរសង្កត់សង្កិន នូវវាទៈដោយវាទៈបាន បពិត្រព្រះគោតមដ៏ចំរើន សេចក្តីចំរើនគួរមានដល់បុរស ព្រោះបានសង្កត់សង្កិននូវដំរីចុះប្រែង សេចក្តីចំរើនមិនគួរមានដល់បុរស ព្រោះសង្កត់សង្កិននូវព្រះគោតមដ៏ចំរើនទេ បពិត្រព្រះគោតមដ៏ចំរើន សេចក្តីចំរើនគួរមានដល់បុរស ព្រោះបានសង្កត់សង្កិន ឬលត់នូវគំនរក្តីដែលកំពុងឆេះ

ន ត្វេវ ភវន្តំ កោតមំ អាសជ្ជ សិយា បុរិសស្ស សោត្ថិភាវោ សិយា បិ នោ កោតម អាសីវិសំ យោវិសំ អាសជ្ជ បុរិសស្ស សោត្ថិភាវោ ន ត្វេវ ភវន្តំ កោតមំ អាសជ្ជ សិយា បុរិសស្ស សោត្ថិភាវោ មយមេវ នោ កោតម ឯសី មយំ បកតិយា យេ មយំ ភវន្តំ កោតមំ ភាវេន ភទ្ទំ អាសាវេតព្ពំ អមញ្ញិម្ហា អធិវាសេតុ(១) មេ ភវំ កោតមោ ស្វាតនាយ ភត្តំ សទ្ធិំ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ សច្ចកោ ឯតទវោច អភិក្កន្តំ ភោ កោតម អភិក្កន្តំ ភោ កោតម ឯតទគ្គំ ភោ កោតម អធិវាសនំ វិទិត្វា តេ លិច្ឆវី អាមន្តេសិ សុណន្តុ មេ ភោន្តោ លិច្ឆវី សមណោ កោតមោ ឯមន្តិតោ ស្វាតនាយ(២) សទ្ធិំ ភិក្ខុសង្ឃេន យេន មេ អភិហារេយ្យាថ យថសរ្ជ បដិរូបំ មញ្ញេយ្យាថាតិ ។

---

១ ម. ឯត្តន្តរេ ចសទ្ទោ ទិស្សតិ ។ ២ ម. ស្វាតនាយ ភត្តំ ។

សេចក្តីចំរើនមិនគួរមានដល់បុរស ព្រោះបានសង្កត់សង្កិនទូវព្រះគោតម
ដ៏ចំរើនទេ បពិត្រព្រះគោតមដ៏ចំរើន សេចក្តីចំរើន គួរមានដល់បុរស
ព្រោះបានសង្កត់សង្កិនទូវអាសិរពិស ដែលមានពិសដ៏ពន្លឹក សេចក្តីចំ-
រើនមិនគួរមានដល់បុរស ព្រោះបានសង្កត់សង្កិនទូវព្រះគោតមដ៏ចំរើនទេ
បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គជាអ្នកកំចាត់បង់ទូវគុណ ខ្ញុំព្រះអង្គ
ជាអ្នកយើសយង្គដោយវាចា ព្រោះហេតុថា ខ្ញុំព្រះអង្គបានសំគាល់ទូវព្រះ
គោតមដ៏ចំរើន ថាជាបុគ្គលគួរសង្កត់សង្កិនទូវវាទៈ ដោយវាទៈបាន សូម
ព្រះគោតមដ៏ចំរើនទទួលភត្តរបស់ខ្ញុំ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ជាមួយនឹង
ភិក្ខុសង្ឃ ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។
លំដាប់នោះ សច្ចកនិគន្ថបុត្រ បានដឹងច្បាស់ទូវកិរិយាទទួលនិមន្ត របស់
ព្រះមានព្រះភាគហើយ ក៏និយាយនឹងព្រះបាទលិច្ឆវីទាំងនោះថា ព្រះបាទ
លិច្ឆវីទាំងឡាយដ៏ចំរើន ចូរស្តាប់ពាក្យរបស់អាត្មា ព្រះសមណគោតម
អាត្មានិមន្តហើយ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ជាមួយនឹងភិក្ខុសង្ឃ បពិត្រ
ទាំងឡាយ គួរយកវត្ថុណាមកឲ្យអាត្មា មួយទៀត វត្ថុណាដែលជារបស់
សមគួរ ដល់ព្រះសមណគោតមនោះ បពិត្រទាំងឡាយ គួរដឹងវត្ថុនោះៗ។

อเจลโก เต ลิจฺฉวี ตสฺสา รตฺติยา อจฺจเยน สกฺก-
กสฺส เทวนฺทสฺส ปญฺหพฺยากรณานิ ปฏิภาตุนฺติ
ญตฺวา เตหิ อภิหารหิ อภิหรีสุ ฯ อเจลโก สกฺโก เทว-
ปุตฺโต สเกน อาภเมฆปฏลาทินา ขาณุมตฺถเก
ปติฏฺฐาเปตฺวา ตสฺมาเตน กาลิเกน อาเกฏกเมเฆน
ตาเฬนฺโต เตสํ เตสญฺจ เทวปุตฺตานนฺติ ฯ

(๔๒) อเจลโก ตสฺส ปุพฺพณฺหสมยนฺติ เสสฺ
ปตฺตจีวรมาทาย เยน สกฺกสฺส เทวนฺทสฺส อาวา-
สโม เตนุปสงฺกมิ อุปสงฺกมิตฺวา ปญฺญตฺเต อาสเน
นิสีทิ สทฺธึ ตทุปิเยน ฯ อเจลโก สกฺโก เทว-
นฺทสฺส เทวปุตฺโต ปุพฺพปฺปฏิปาฏิยา ตทุปิเยน
ขาณุมตฺถเก ปติฏฺฐาปิเต เตเชน อาเกฏกเมเฆน
ตาเฬนฺเต สญฺชานิ ฯ อเจลโก เอวมาห ‘‘ยาวญฺจิทํ
ภนฺเต อิทฺธานุภาโว ยาวญฺจิทํ มหานุภาวตา ยตฺร
หิ นาม อิมสฺมิมฺปิ ปาสาเณ ปทุมานิ ชายิสฺสนฺติ
ปทุมานิ วิรูหิสฺสนฺติ ปทุมานิ สมฺปชฺชิสฺสนฺตี’’ติ ฯ
อเจลโก สกฺโก เทวนฺทสฺส เทวปุตฺโต ตสฺมาเตน
ปาสาเณน ปทุมานิ ชายิสฺสนฺติ ปทุมานิ วิรูหิสฺสนฺติ
ปทุมานิ สมฺปชฺชิสฺสนฺตีติ ยถาภูตญฺจ ตถาคตสฺส
ปุญฺญานิ จ ตญฺจ ฌานสฺส สุขายาติ ฯ

លុះកន្ទឹកត្រីនោះទៅហើយ ទើបព្រះចាតុលិច្ឆវាំងនោះ ក៏នាំទូវកត្តា-
តិហារប្រមាណ ៥០០ សម្រាប់ដល់សច្ចកនិគន្ថបុត្រ ។ លំដាប់នោះ
សច្ចកនិគន្ថបុត្រចានតាក់តែងនូវខាទនីយៈទឹងភោជនីយៈដ៏ឧត្តម ក្នុងអាវាម
របស់ខ្លួនហើយ ចាត់បម្រើទៀរទៅក្រាបទូលកត្តកាល ដល់ព្រះមានព្រះ
ភាគថា បពិត្រព្រះគោតមដ៏ចំរើន កាលគួរហើយ កត្តក៏សម្រេចហើយ ។

(៤៤) លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់ដោយ
ចាត្រចីវរក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅកាន់អាវាមរបស់សច្ចក និ-
គន្ថបុត្រ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេរៀបចំថ្វាយ
ជាមួយនឹងភិក្ខុសង្ឃ ។ គ្រានោះឯង សច្ចកនិគន្ថបុត្រក៏អង្គាសព្រះភិក្ខុ-
សង្ឃមានព្រះពុទ្ធជាប្រធានឲ្យឆានឆ្អែតស្កប់ស្កល់ ដោយខាទនីយៈ នឹង
ភោជនីយាហារដ៏ឧត្តម ដោយដៃរបស់ខ្លួន ត្រាតែភិក្ខុសង្ឃហាមឃាត់ ។
គ្រានោះ សច្ចកនិគន្ថបុត្រកំណាត់ដីងថា ព្រះមានព្រះភាគទ្រង់ឆានរួច
ហើយ ដាក់ព្រះហស្តចុះចាកចាត្រហើយ ក៏កាន់យកនូវអាសនៈទាប
មួយ អង្យកង្គីដ៏សមគួរ ។ លុះសច្ចកនិគន្ថបុត្រអង្គុយក្នុងអង្គីដ៏សមគួរ
ហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំ-
រើន បុណ្យណាដែលមានក្នុងទាននេះផង បុណ្យវិសែសអំពីទាននេះផង ក៏
បុណ្យនោះឯង ចូរប្រព្រឹត្តទៅដើម្បីសេចក្តីសុខដល់ខាយកតំរិត្បាយ ។

យំ ខោ អក្ខវេសច្ឆន តាឝិសំ ឧក្ខិណោយ្យំ អាកម្ម អវីតរាគំ អវីតទោសំ អវីតមោហំ តំ ឆាយគាឝំ ភវិស្សតិ យំ ខោ អក្ខវេសច្ឆន មាឝិសំ ឧក្ខិណោយ្យំ អាកម្ម វីតរាគំ វីតទោសំ វីតមោហំ តំ ភុយ្យោ ភវិស្សតីតិ ។

ចូឡសច្ចកសុត្តំ បញ្ចមំ និដ្ឋិតំ ។

ព្រះសម្ពុទ្ធបរមគ្រូ ទ្រង់មានព្រះពុទ្ធដីកាថា ម្នាលអគ្គិវេស្សវៈ បុណ្យ
ណាមួយ ដែលអាស្រ័យនូវខន្តិណេយ្យបុគ្គលប្រាកដដូចអ្នក ដែលជា
បុគ្គលមិនទាន់ប្រាសចាកពាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់
ប្រាសចាកមោហៈ បុណ្យនោះនឹងកើតមានដល់ពាយកចំណែកខ្លាយ នៃ
អគ្គិវេស្សនៈ មួយទៀត បុណ្យណា ដែលអាស្រ័យនូវខន្តិណេយ្យ-
បុគ្គលប្រាកដដូចជាតថាគត ជាបុគ្គលប្រាសចាកពាគៈ ប្រាសចាក
ទោសៈ ប្រាសចាកមោហៈហើយ បុណ្យនោះនឹងកើតមានដល់អ្នក ។

ចប់ ចូឡសច្ចកសូត្រ ទី ៥ ។

ឆដ្ឋំ មហោសធកសុត្តំ

(៤៩) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន ភគវា បុព្ពណ្ហសមយំ សុនិវត្ថោ ហោតិ បត្តចីវរមាទាយ វេសាលិយំ បិណ្ឌាយ បវិសិតុកាមោ ។ អថខោ សម្ពហុលា ឯកន្តបុត្តិកា ឆន្ទាវិហារិំ អនុចង្កមមានោ អនុវិចរមានោ យេន មហាវនំ កូដាគារសាលា តេនុបសង្កមិ ។ អទ្ទសា ខោ អាយស្មា អានន្ទោ សម្ពហុលំ ឯកន្តបុត្តិំ ទូរតោវ អាគច្ឆន្តិំ ទិស្វាន ភគវន្តិំ ឯតទវោច អយំ ភន្តេ សម្ពហុលា ឯកន្តបុត្តិកា អាគច្ឆតិ ភទ្ទប្បកាវ ទិតោ បណ្ឌិតកាវ នោ សាធុសម្មតោ ពហុជនស្ស ឯសោ ខោ ភន្តេ អវណ្ណកាមោ ពុទ្ធស្ស អវណ្ណកាមោ ធម្មស្ស អវណ្ណកាមោ សង្ឃស្ស សាធុ ភន្តេ ភគវា មុហុត្តំ ឯសីទតុ អនុកម្បំ ឧបាទាយាតិ ។ ឯសីទិ ភគវា បញ្ញត្តេ អាសនេ ។ អថខោ សម្ពហុលា ឯកន្តបុត្តិកា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា

មហាសច្ចកសូត្រ ទី ៦

(៤៥) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះ
ភាគទ្រង់គង់នៅក្នុងកូដាគារសាលា នាមហាវ័ន ទៀបក្រុងវេសាលី ។
សម័យនោះឯង ព្រះមានព្រះភាគទ្រង់ស្បង់ដោយល្ងាច ប្រដាប់ជាត្រៃចីវរ
ក្នុងបុព្វណ្ហសម័យ ស្តេចព្រះដំណើរចូលទៅក្នុងក្រុងវេសាលី ដើម្បី
បិណ្ឌបាត ។ គ្រានោះ សច្ចកនិគន្ថបុត្រ កំពុងចង្រ្កម កំពុងគ្រាច់
ទៅដោយលំដាប់ៗ ដើម្បីសម្រាកស្មង់ ហើយចូលទៅកាន់កូដាគារសាលា
នាមហាវ័ននោះ ។ ព្រះអានន្ទ មានអាយុ បានឃើញសច្ចកនិគន្ថ-
បុត្រ កំពុងតែដើរមកអំពីចម្ងាយ លុះបានឃើញហើយ ក៏ក្រាបបង្គំទូល
ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សច្ចកនិគន្ថបុត្រនេះ
ជាអ្នកពោលតិរច្ឆានកថា ជាអ្នកពោលថាខ្លួនជាអ្នកប្រាជ្ញ ជនច្រើននាក់
សន្មតគាត់ថាជាអ្នកត្រឹមត្រូវ ឥឡូវនេះកំពុងដើរមក បពិត្រព្រះអង្គដ៏ចំ-
រើន សច្ចកនិគន្ថបុត្រនេះ ជាអ្នកប្រាថ្នារកទោសព្រះពុទ្ធ ប្រាថ្នារកទោស
ព្រះធម៌ ប្រាថ្នារកទោសព្រះសង្ឃ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមាន
ព្រះភាគ ទ្រង់គង់មួយរំពេច អាស្រ័យសេចក្តីអនុគ្រោះ ។ ព្រះ
មានព្រះភាគទ្រង់គង់លើអាសនៈ ដែលគេតាក់តែងហើយ ។ គ្រានោះ
សច្ចកនិគន្ថបុត្រ ក៏ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ

กตมา สนฺติ สมฺโภเท สมฺโภทนียา กามา สาก-
ณฺฑปิยา รตฺตสาเรฏฺฐา ฯเปฯ ตตฺถ กตมา สนฺติ ฯ

(๘๖) ฯเปฯ ตตฺถ กตมา ติสฺโส เวทนา ติ-
กฺขปฺปตฺตา กตมา ทุกฺขา เวทนา สนฺติ เห เหตฺถ
ฯเปฯ สมณา พฺราหฺมณา กายกาวาตา นุโยคมนุ-
ยุตฺตา วิหรนฺติ เอเต เปตฺถ กาวาตา ฯ ตตฺถ สนฺติ หิ(๑) เห
เหตฺถ สารีรกา ทุกฺขเวทนา(๒) ฯ ภูตปุพฺพี เห
เหตฺถ สารีรกาย ทุกฺขาย เวทนาย ปฏิฆสฺส
สเหตุ ปาตุภาเวปิ ตาม ภาวิตตฺตา ทานยมฺปิ
ตาม ปลิสฺสตฺตา ปุญฺญมฺปิ เหตาทิตา มุขเหตุ ทุกฺ-
ขมิสฺสตฺตา ทุมฺทานมฺปิ ตาปุณาสฺสตฺตา(๓) ปตฺตกฺเขปิ ฯ
ตสฺส เอเต ปตา เห เหตฺถ กายนฺวยา ปตฺตา
เหตา ตายสฺส ภาเสน ภาวิตา ตา กาสฺส เหตุ
อภาวิตตฺตา ปตฺตสฺส ฯ สนฺติ ปน เห เหตฺถ
เอเต สมณา พฺราหฺมณา ปตฺตกาวาตา นุโยคมนุยุตฺตา

---

๑ ม. หิ เต ฯ ๒ ม. ทุกฺขา เวทนา ฯ ๓ ม. ปาปุณิสฺสตฺตา ฯ

កំធ្វើសេចក្តីវិតកយ មួយអន្ទើយោយព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួរវិតកយ ទើងពាក្យដែលគួរលើកហើយ ក៏អង្គុយក្នុងទីសមគួរ ។

[៤៦] លុះសច្ចកនិគន្ថបុត្រ អង្គុយនៅក្នុងទីសមគួរហើយ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើនមានសមណ-ព្រាហ្មណ៍ពួកមួយ ខ្ញុំលំអាយក្នុងការប្រកបរឿយ ។ នូវកាយការវិនា(១) (វិបស្សនា) មិនបានខ្ញុំលំអាយក្នុងការប្រកបរឿយ ។ នូវចិត្តការវិនា(២) (សមថៈ) ឡើយ ។ បពិត្រព្រះគោតមដ៏ចំរើន សមណព្រាហ្មណ៍ទាំងនោះតែងបាននូវទុក្ខវេទនា ដែលកើតឡើងក្នុងសរីរៈ ។ បពិត្រព្រះគោតមដ៏ចំរើន រឿងពីរដ្ឋាប់មានមកថា បុគ្គលដែលមានទុក្ខវេទនាកើតឡើងក្នុងសរីរៈពាល់ត្រូវហើយ ទើងត្រឡប់ទៅជាមនុស្សរឹងក្អេងក្អាងមាន បេះដូងទើងបែកឆ្អាយក៏មាន ឈាមក្តៅទើងក្អួតចេញអំពីមាត់ក៏មាន សមណ-ព្រាហ្មណ៍ទាំងនោះ ទើងដល់នូវកិរិយាធ្លុតកយមាយចិត្តក៏មាន ។ បពិត្រព្រះគោតមដ៏ចំរើន ចិត្តនុ៎ះ របស់បុគ្គលនោះឯង រមែងប្រព្រឹត្តទៅតាមកាយ តែងប្រព្រឹត្តទៅដោយអំណាចនៃកាយ សេចក្តីនោះព្រោះហេតុដូចម្តេច ព្រោះថាបុគ្គលនោះមិនបានអប់រំចិត្ត ។ បពិត្រព្រះគោតមដ៏ចំរើន មួយទៀត មានសមណព្រាហ្មណ៍ពួកមួយ ពុនខ្ញុំលំអាយក្នុងការប្រកប

---

១ ការអប់រំកាយ ។ ២ ការអប់រំចិត្ត ។

วิหารนฺติ เถเร กายคตาสึ ๆ ฉสนฺติ หิ เอเก เถรสมา เขตสิกึ ทุกฺขึ เวทนึ ๆ ภูตปุพฺพึ เอเก เถรสมา เขตสิกาย ทุกฺขาย เวทนาย ฉฏฺฐสฺส สเตฺถ ฆานกฺขเยปิ ถาม กวิสฺสติ ชาตยมฺปิ ถาม ฉลิ-สฺสติ ฉณฺหมฺปิ เลาหิตึ มุขเต ฉกฺขมิสฺสติ ฉมฺหา-ทมฺปิ ชาปุฬิสฺสนฺติ จิตฺตกฺเขปึ ๆ ตสฺส เถเร เอเส เอเก เถรสมา จิตฺตนฺยเย กายเย เยหิ จิตฺตสฺส วเสน วตฺตึ ตึ กิสฺส เหตุ อกาวิตตฺตา กายสฺส ๆ ตสฺส มยฺหึ เอเก เถรสมา ยึ เยหิ อหฺหา เอเต เถรสมสฺส สาวกา จิตฺตกาวนา-ทุเยกมนุยุตฺตา วิหารนฺติ เถเร กายคตาสนฺติ ๆ

(๔๗) กิญฺจิ ปน เต อกฺขิเวสฺสน กายคตาสึ สุตึ ๆ เสยฺยถีทึ ธเญฺญ วเญฺญ กิเส สญฺญิเญฺญ มกฺขเล เถเสเล ฝเต หิ เอเก เถรสมา อเจล-กา มุตฺตาจาก หตฺถาเลขกา ธ ฝหิกธนฺติกา

រឿយ ។ នូវចិត្តការនា មិនឃ្លាងខ្ជាយក្នុងការប្រកបរឿយ ។ នូវកាយ. ការនាឡើយ ។ បពិត្រព្រះគោតមដ៏ចំរើន ក៏សមណព្រាហ្មណ៍ទាំងនោះ តែងបាននូវទុក្ខវេទនា ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ បពិត្រព្រះគោតមដ៏ចំរើន រឿងព៌ាធ្លាប់មានមកថា បុគ្គលដែលមានទុក្ខវេទនាប្រព្រឹត្តទៅក្នុងចិត្តពាល់ត្រូវហើយ ទំងត្រឡប់ទៅជាមនុស្សរឹងភ្លៅក៏មាន បេះដូងទំងបែកធ្លាយក៏មាន ឈាមក្តៅទំងក្អួតចេញអំពីមាត់ក៏មាន សមណព្រាហ្មណ៍ទាំងនោះ ទំងដល់នូវកិរិយាធ្លុតពាយមាយចិត្តក៏មាន ។ បពិត្រព្រះគោតមដ៏ចំរើន កាយនុ៎ះ របស់បុគ្គលនោះឯង រមែងប្រព្រឹត្តទៅតាមចិត្ត តែងប្រព្រឹត្តទៅដោយអំណាចនៃចិត្ត សេចក្តីនោះព្រោះហេតុដូចម្តេច ព្រោះថាបុគ្គលនោះមិនបានអប់រំកាយ ។ បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គគិតយ៉ាងនេះថា សាវ័កទាំងឡាយ របស់ព្រះគោតមដ៏ចំរើន តែងខ្ជាយក្នុងការប្រកបរឿយ ។ នូវចិត្តការនា តែមិនបានខ្ជាយក្នុងការប្រកបរឿយ ។ នូវកាយការនាឡើយ ។

(๔๗) ម្នាលអគ្គិវេស្សនៈ ចុះកាយការនា អ្នកបានឮមកដូចម្តេច ។ សច្ចកនិគន្ថបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន អាចារ្យទាំងនេះ គឺ នន្ទវច្ឆៈ១ កិសសង្កិច្ចៈ១ មក្ខលិគោសាល ១ ជាអ្នកប្រព្រឹត្តលះបង់មារយាទល្អ ស៊ីលទ្ធដៃ គេហៅថា អ្នកដ៏ចំរើនចូរមក

ฉ ตีณฺฑกฉณฺฑีกา ฉ อกีตหาฑี ฉ ขุฏฺฐิสฺส กาตี ฉ
ฉีมณฺฑี สาธีนฺตี เต ฉ กุมฺภีมุขา ปฑีกฺกณฺหาฑี ฉ
กาลาปีมุขา ปฑีกฺกณฺหาฑี ฉ ฬิงฺคกมณฺฑี ฉ ฉณฺหมณฺฑี
ฉ มูสลมณฺฑี ฉ ทีฆีฑี กุญฺชราสีสี ฉ กณฺฑีนีโย
ฉ ตายมาตายา ฉ ปุริสฺสาคตายา ฉ สณฺฐีตีสุ ฉ
ยตฺถ สา ขุปฏฺฐีตา ปีตา ฉ ยตฺถ มกฺกีกา สณฺห-
สณฺหตาวีลี ฉ มฏฺฐี ฉ มีสี ฉ สุรี ฉ มีรยี
ฉ ชุสีฉกี ปีวีลี เต ฬกาการีกา ภ ปีตี
ฬกาลาปีกา ฐาการีกา ภ ปีตี ฐาลาปีกา
ฯ ปี ฯ สณฺหการีกา ภ ปีตี สณฺหาลาปีกา

ក៏មិនព្រមមក គេយាត់ថា អ្នកដ៏ចំរើនឈប់សិន ក៏មិនព្រមឈប់ មិនត្រេកអរនឹងចង្ហាន់ដែលគេនាំមកមុន មិនត្រេកអរនឹងចង្ហាន់ដែលគេនាំមកចំពោះខ្លួន មិនត្រេកអរនឹងកិច្ចនិមន្ត អចេលក៏ចាំនុ៎ះមិនខ្ជួលចង្ហាន់ដែលគេនាំចេញអំពីមាត់ឆ្នាំងហើយឲ្យ មិនខ្ជួលចង្ហាន់ដែលគេនាំចេញអំពីមាត់ក្តោរហើយឲ្យ មិនខ្ជួលចង្ហាន់ដែលគេដើរកន្ទុំឆ្លងរណើហើយនាំមកឲ្យ មិនខ្ជួលចង្ហាន់ដែលគេដើរកន្ទុំកណាត់ឈើ ហើយនាំមកឲ្យ មិនខ្ជួលចង្ហាន់ដែលគេដើរកន្ទុំអង្រែហើយនាំមកឲ្យ មិនខ្ជួលចង្ហាន់អំពីដៃមនុស្សពីរនាក់កំពុងបរិភោគ មិនខ្ជួលចង្ហាន់អំពីដៃស្រីមានគភ៌ មិនខ្ជួលចង្ហាន់អំពីដៃស្រីដែលកំពុងបំបៅកូន មិនខ្ជួលចង្ហាន់អំពីដៃស្រីដែលកំពុងគាន់បុរសដទៃ មិនខ្ជួលចង្ហាន់ ក្នុងកន្លែងដែលវៃត្តិបានមក(១) មិនខ្ជួលចង្ហាន់កងកន្លែងដែលមានឆ្កែនៅចាំ មិនខ្ជួលចង្ហាន់ត្រង់កន្លែងដែលមានរុយកេមចាំងហូរ មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកថ្នាំត្រាំ មួយទៀត អចេលក៏ចាំនោះខ្ជួលចង្ហាន់ចំពោះតែកន្ធក់ផ្លុំមួយ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយហុយតែមួយដុំខ្លះ ខ្ជួលចង្ហាន់ចំពោះតែកន្ធក់ផ្លុំពីរ ញុំាងអត្តភាពឲ្យប្រព្រឹត្ត ទៅ ដោយហុយតែពីរដុំខ្លះ ។ បេ ។ ខ្ជួលចង្ហាន់ចំពោះតែកន្ធក់ផ្លុំ ៧

---

១ ពួកសិស្សរបស់អចេលក៏តែងនាំគ្នាយៃកវត្ថុមានអង្ករជាដើម អំពីទីនោះ ។ មកចំអិនបាយដើម្បីប្រគេនដល់ពួកអចេលក៏ក្នុងសម័យមានបាយប្រុ អចេលក៏ដែលប្រព្រឹត្តវត្តខ្រៃដ្ឋមិនខ្ជួលយកចង្ហាន់នោះឡើយ ។ អដ្ឋកថា ។

ឯកាសិស្សាបិ ឧត្តរិយា យាវេត្ថ ទ្វីហាបិ ឧត្តរិ យាវេត្ថ ។ បេ ។ សត្តហាបិ ឧត្តរិ យាវេត្ថ ឯកាហាបិ កប្បំ អាហារំ អាហារេត្វា ទ្វីហាបិ កប្បំ អាហារំ អាហារេត្វា ។ បេ ។ សត្តាហាបិ កប្បំ អាហារំ អាហារេត្វា ឥតិ ឯវរូបំ អឌ្ឍមាសិកម្បិ បរិយោ យកត្តកោដនាឌុយោគមនុយុត្តា វិហរន្តីតិ ។ កឹ បន តេ អង្គវេស្សន តាវតកេនេវ យាវេន្តីតិ ។ នោ ហិទំ កោ កោតម អវេច្ចកនា កោ កោតម ឧឡ្ឋាកនំ ឧឡ្ឋាកនំ ទានន័យានំ ទានន្តិ ឧឡ្ឋាកនំ ឧឡ្ឋាកនំ កោដនានំ ភុញ្ជន្តិ ឧឡ្ឋាកនំ ឧឡ្ឋាកនំ សាយនីយានំ សាយន្តិ ឧឡ្ឋាកនំ ឧឡ្ឋាកនំ ឥតានំ បិវន្តិ តេ ឥមំ កាយំ ពលំ កាហេន្តិ ឥម ព្រូហេន្តិ ឥម មេទេន្តិ ឥមាតិ ។ យំ ខោ តេ អង្គ-វេស្សន ឧបរិមំ បហាយ បច្ចា ឱបចិនន្តិ ឯវំ ឥមស្ស កាយស្ស អាចយាបចយោ ហោតិ ។

ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយចាយ ៧ ដុំខ្លះ ញ៉ាំងអត្តភាពឲ្យប្រ-
ព្រឹត្តទៅដោយចង្ហាន់ កន្លះកាដន់តូចមួយខ្លះ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ
ដោយចង្ហាន់ កន្លះកាដន់តូចពីរខ្លះ ។ បេ ។ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្ត
ទៅដោយចង្ហាន់ កន្លះកាដន់តូច ៧ ខ្លះ ស៊ីអាហារខានមួយថ្ងៃខ្លះ ស៊ី
អាហារខានពីរថ្ងៃខ្លះ ។ បេ ។ ស៊ីអាហារខាន ៧ ថ្ងៃខ្លះ តែងខ្វល់
ខ្វាយក្នុងការប្រកបរឿយ ។ នូវការបរិភោគចាយផ្ទាស់ប្តូរថ្ងៃអស់កន្លះខែ
មានសភាពយ៉ាងនេះដូច្នេះខ្លះ ។ នែអគ្គិវេស្សន: អចេលក៍ ពាំងនោះ
តែងញ៉ាំងអត្តភាពឲ្យប្រព្រឹត្ត ដោយហេតុមានប្រមាណតែប៉ុណ្ណោះឬ ។
បពិត្រព្រះគោតមដ៏ចំរើន ហេតុនេះមិនមែនមានតែប៉ុណ្ណោះទេ បពិត្រព្រះ
គោតមដ៏ចំរើន អចេលក៍ពាំងនោះ ឆួនកាលពំពាស៊ីនូវខាទនីយៈពាំង
ឡាយដ៏ខ្ពត់មកក្រៃលែង បរិភោគនូវភោជនពាំងឡាយ ដ៏ខ្ពត់មកក្រៃលែង
ក្រេបផ្សាប នូវសាយនីយៈពាំងឡាយ ដ៏ខ្ពត់មកក្រៃលែង ផឹកនូវទឹកពាំង
ឡាយដ៏ខ្ពត់មកក្រៃលែង អចេលក៍ ពាំងនោះ ឈ្មោះថា ញ៉ាំងកាយ
នេះឲ្យកាន់យកនូវកំឡាំង ឲ្យចំរើន ឲ្យធាត់ធំ ។ ម្នាលអគ្គិវេស្សន: ត្រង់
ដែលអចេលក៍ ពាំងនោះ លះបង់នូវអំពើកម្រក្នុងកាលមុន ហើយសង្រួ
នូវខ្លួន មានខាទនីយៈជាដើម ក្នុងកាលជាខាងក្រោយ កាលបើធ្វើយ៉ាង
នេះ ការចំរើននឹងការមិនចំរើនរបស់កាយនេះ តែងតែមាន ។

(๒๘) ตตฺถ ยถา เต อคฺคิเวสฺสน จตุตฺถภาณวาสุตาติ ฯ จตุตฺถภาณวารายเยว สจฺจเกน นิคณฺฐปุตฺเตน สทฺธิ สมาคโต น สมฺปายเมว ฯ อยเญหิ ภควา สจฺจกสฺส นิคณฺฐปุตฺตสฺส ปตฺตธาเรน ยาปิโต เหติ เต ปนสฺส อคฺคิเวสฺสน ปุริมา ตายภาณวาภาณวาติ สาปิ อรียสฺส วินเย เอว ธมฺมิกา กา.ยภาณวา ตายภาณวมฺปิ(๑) เหติ ตุมฺเห อคฺคิเวสฺสน น อญฺญาเสิ กุโต ปน ตุมฺเห จตุตฺถภาณวนฺติ สญฺญิโน อปิจ อคฺคิเวสฺสน ยถา อภาวิตกายา ๘ เหตเว อ.ภาวิตจิตฺตา ๘ ภาวิตกายา ๘ เหตเว(๒) ภาวิต.จิตฺตา ๘ นาม สุฌาหิ สาธุกนฺติ ปนสิตเวหิ ภาสิสฺสามีติ ฯ ฯปิ เหติ เหเว สจฺจเกน นิ.คณฺฐปุตฺเตน ภควาโต ปฏิสฺสุตนฺติ ฯ

---

๑ ฉ. ม. ตายภาณวนฺติ ปิ ฯ ๒ ฉ. เหเวติ ๘ ทิสฺสติ ฯ

(๘๙) ម្នាលអគ្គិវេស្សនៈ ចុះចំណែកខាងចិត្តភាវនា អ្នកបានឮមកដូចម្តេច ។ សច្ចកនិគន្ថបុត្រ កាលព្រះមានព្រះភាគទ្រង់សួរហើយក៏ចិត្តភាវនា ក៏មិនអាចនឹងដោះស្រាយបាន ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះនឹងសច្ចកនិគន្ថបុត្រថា នែអគ្គិវេស្សនៈ កាយ-ភាវនាណា ដែលអ្នកបានអប់រំហើយ កន្លងកាលមុន កាយភាវនានោះមិនប្រកបដោយធម៌ កន្លងអរិយវិន័យទេ ម្នាលអគ្គិវេស្សនៈ អ្នកមិនអាចដឹងសូម្បីនូវកាយភាវនា តើនឹងអាចដឹងនូវចិត្តភាវនាដូចម្តេចបាន ម្នាលអគ្គិវេស្សនៈ ក៏ឯបុគ្គលមិនបានអប់រំកាយផង មិនបានអប់រំចិត្តផង បុគ្គលបានអប់រំកាយផង បានអប់រំចិត្តផង ដោយប្រការណា អ្នកចូរស្តាប់នូវប្រការនោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែងឥឡូវនេះ ។ សច្ចកនិគន្ថបុត្ត ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

